លទ្ធផលនៃការស្រាវជ្រាវសកម្មភាព
ដែលដឹកនាំដោយសហគមន៍

# ការសង្កេតរបស់ប្រជាជនទៅលើការប្រែប្រួលរបស់ទន្លេ និងផលប៉ះពាល់របស់វា

## ភូមិកោះច្បារ និងភូមិចារថ្នោល



INTERNATIONAL RIVERS
people • water • life

FLO

របាយការណ៍នេះត្រូវបានសហការបោះពុម្ពដោយ អង្គការទន្លេអន្តរជាតិ (International Rivers) អង្គការស្ម័គ្រចិត្តដើម្បីសង្គម (CVS) និងអង្គការដើម្បីជីវភាពនិងព្រៃឈើ (FLO)។

រចនាក្រាហ្វិកដោយ៖ ជឹម ចំរើន

គម្របមុខនិងក្រោយ៖ ទន្លេមេគង្គនាពេលថ្ងៃលិច កាំពី ខេត្តក្រចេះ ឆ្នាំ2022។
រូបថតដោយ៖ ជឹម ចំរើន

គាំទ្រដោយ៖ មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគម្រាមកំហែង (CEPF) ដែលជាកិច្ចផ្តួចផ្តើមរួមគ្នារបស់មូលនិធិសប្បុរស ម៉ាហ្គារ៉េត ខាហ្គីល (MACP), ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង, អង្គការអភិរក្សអន្តរជាតិ, សហភាពអឺរ៉ុប, មូលនិធិបរិក្ខារបរិស្ថានសកល (GEF), រាជរដ្ឋាភិបាលជប៉ុន, និងធនាគារពិភពលោក ក្នុងគោលបំណងធានាឱ្យសង្គមស៊ីវិលបានចូលរួមនៅក្នុងការអភិរក្សជីវចម្រុះ។

# មាតិកា

1. សេចក្តីផ្តើម ........ 1

2. ទីតាំងនៃការសិក្សាស្រាវជ្រាវ៖ ភូមិកោះច្បារ និងភូមិចារថ្មោល ស្រុកសំបូរ ខេត្តក្រចេះ ........ 3

3. គោលបំណង ដំណើរការ និងអ្នកចូលរួម របស់ការស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍ ........ 7

3.1 ដំណើរការនៃការស្រាវជ្រាវកម្មភាពដែលដឹកនាំដោយសហគមន៍ ........ 9

3.2 អ្នកចូលរួមក្នុងការស្ទង់មតិអំពីការស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍ ........ 13

4. លទ្ធផល៖ ការប្រែប្រួលនៃទន្លេ និងផលប៉ះពាល់ទៅលើជីវភាពរស់នៅរបស់ប្រជាជន ........ 14

4.1 ការថយចុះបរិមាណត្រី ........ 15

4.2 កសិកម្ម និងការចិញ្ចឹមសត្វតាមមាត់ទន្លេ ........ 18

4.3 ការថយចុះគុណភាពទឹក ........ 21

4.4 ការប្រែប្រួល និងផលប៉ះពាល់ផ្សេងទៀតដែលបានរកឃើញក្នុងពេលសិក្សាស្រាវជ្រាវ ........ 22

4.5 ការយល់ដឹងរបស់ប្រជាជនអំពីមូលហេតុនៃការប្រែប្រួលរបស់ទន្លេ ........ 25

5. សេចក្តីសន្និដ្ឋាន និងជំហានបន្ទាប់ ........ 26

ឯកសារឧបសម្ពន្ធ ........ 28

ឧបសម្ពន្ធទី1៖ ក្រុមការងារស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍ ភូមិកោះច្បារនិងភូមិចារថ្មោល ........ 30

ឧបសម្ពន្ធទី2៖ មុខរបររបស់ប្រជាជនដែលចូលរួមឆ្លើយសំណួរស្ទង់មតិ នៅភូមិកោះច្បារនិងភូមិចារថ្មោល ........ 31

ឧបសម្ពន្ធ**3**ក៖ បរិមាណត្រីដែលរកបានក្នុងមួយជើង- 10ឆ្នាំមុនធៀបនឹងឆ្នាំ2022 ........ 32

ឧបសម្ពន្ធ3ខ៖ ពូជត្រីដែលរកបាននៅភូមិកោះច្បារ និងភូមិចារថ្មោលក្នុងឆ្នាំ2022 ........ 34

ឧបសម្ពន្ធទី3គ៖ ពូជត្រីកម្រឃើញមាន ឬកម្ររកបាននៅឆ្នាំ2022 នៅភូមិកោះច្បារ និងភូមិចារថ្មោល ........ 36

ឧបសម្ពន្ធទី3ឃ៖ ពូជត្រីដែលលែងឃើញមាន ឬរកលែងបាននៅឆ្នាំ2022 ........ 38



អ្នកកត្រីម្នាក់កំពុងពិនិត្យមើលមងរបស់គាត់, ទន្លេមេគង្គ, ភូមិកោះច្បារ, ឆ្នាំ2022។ រូបថត៖ ជឹម ចំរើន

# 1. សេចក្តីផ្តើម

ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ អ្នកភូមិកោះច្បារ និងភូមិចារថ្នោលដែលរស់នៅតាមដងទន្លេមេគង្គក្នុងស្រុកសំបូរ ខេត្តក្រចេះ នៃប្រទេសកម្ពុជាបានសង្កេតឃើញមានការផ្លាស់ប្តូរយ៉ាងខ្លាំងទៅលើប្រព័ន្ធអេកូឡូស៊ីទន្លេ និងប្រព័ន្ធធនធានធម្មជាតិដែលពួកគាត់ពឹងអាស្រ័យសម្រាប់ជីវភាព ជាពិសេស ការប្រែប្រួលនៃកម្រិតទឹកឡើងឬស្រកក្នុងកម្រិតមិនអាចស្មានបាននិងក្នុងរយៈពេលមិនទៀងទាត់ ការថយចុះនូវបរិមាណត្រី និងធនធានមច្ឆាឬរុក្ខជាតិនានា និងការហូរច្រោះច្រាំងទន្លេ ដែលជាសញ្ញាបង្ហាញថាទន្លេកំពុងរងគ្រោះថ្នាក់។ ដោយសង្កេតឃើញមានការផ្លាស់ប្តូរទាំងនេះ អ្នកភូមិបានសម្រេចចងក្រងទុកអំពីការផ្លាស់ប្តូរ និងផលប៉ះពាល់ទាំងនេះដែលកើតមានទៅលើជីវិត និងជីវភាពរស់នៅរបស់ពួកគាត់ តាមទស្សនៈនិងបទពិសោធន៍រស់នៅជាក់ស្តែងរបស់ពួកគាត់។

ប្រជាជនក្នុងភូមិបានចូលរួមក្នុងការស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍ និងមានការគាំទ្រពីទីប្រឹក្សានៃអង្គការទន្លេអន្តរជាតិ និងអង្គការអ្នកស្ម័គ្រចិត្តដើម្បីសង្គម ដើម្បីប្រមូលនិងវិភាគទិន្នន័យ ដោយយោងទៅតាមចំណេះដឹងមូលដ្ឋាននិងបទពិសោធន៍រស់នៅជាក់ស្តែង។ លទ្ធផលនៃការស្រាវជ្រាវត្រូវបានសង្ខេបនៅក្នុងរបាយការណ៍នេះ ដើម្បីចែករំលែកជាមួយប្រជាជនក្នុងសហគមន៍ ក៏ដូចជាភាគីពាក់ព័ន្ធនានាដូចជា អង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋាភិបាលផងដែរ។ គេសង្ឃឹមថា លទ្ធផលនៃការស្រាវជ្រាវដែលដឹកនាំដោយសហគមន៍នេះ នឹងត្រូវបានប្រើជាប្រយោជន៍ ដើម្បីផ្តល់ព័ត៌មានដល់ប្រជាជនក្នុងសហគមន៍ និងភាគីពាក់ព័ន្ធនានាសំដៅរួមចំណែករក្សាគ្រប់គ្រង និងអភិរក្សទន្លេនិងធនធានធម្មជាតិឱ្យបានកាន់តែប្រសើរ ដោយទទួលស្គាល់ ផ្តល់តម្លៃ និងរៀសូត្រពីបទពិសោធន៍រស់នៅជាក់ស្តែងរបស់ប្រជាជនមូលដ្ឋាន។ ក្រៅពីនេះ ការស្រាវជ្រាវនេះក៏ជាការចំណែកដល់ផែនការអភិវឌ្ឍន៍ដែលដឹកនាំដោយសហគមន៍ផងដែរ ដើម្បីដោះស្រាយបញ្ហាប្រឈមសំខាន់ៗ រួមទាំងបញ្ហាមួយចំនួនដែលមានបញ្ជាក់ក្នុងរបាយការណ៍នេះ និងកែលម្អស្ថានភាពបរិស្ថាន និងសេដ្ឋកិច្ចសង្គមសម្រាប់ប្រជាជននៅសហគមន៍កោះច្បារ និងចារថ្នោល។

របាយការណ៍នេះបង្ហាញអំពីដំណើរការ និងលទ្ធផលសំខាន់ៗនៃការស្រាវជ្រាវដែលដឹកនាំដោយសហគមន៍ដែលធ្វើឡើងនៅក្នុងភូមិកោះច្បារ និងភូមិចារថ្នោល។ ផ្នែកទីមួយមានបង្ហាញដោយសង្ខេបអំពីទិដ្ឋភាពនៃសហគមន៍ទាំងពីរ។ ផ្នែកទីពីររៀបរាប់អំពីដំណើរការនៃការស្រាវជ្រាវដែលដឹកនាំដោយសហគមន៍។ ផ្នែកទីបីសង្ខេបអំពីលទ្ធផលសំខាន់ៗមួយចំនួនទាក់ទងនឹងស្ថានភាពផ្លាស់ប្តូររបស់ទន្លេ និងផលប៉ះពាល់ទៅលើជីវភាពរស់នៅរបស់ប្រជាជន។ នៅក្នុងផ្នែកបញ្ចប់ របាយការណ៍នេះមានបង្ហាញផងដែរនូវសកម្មភាពដែលគួរអនុវត្តក្នុងជំហានបន្ទាប់។




ប្រភព៖ OpenStreetMap, 2023
ផែនទីនេះត្រូវបានសម្រួលឱ្យសាមញ្ញ និងងាយមើល ដោយបានលុបចេញនូវសញ្ញាសម្គាល់ព្រំដែន ផ្លូវ និងកន្លែងតូចៗមួយចំនួន។



# 2. ទីតាំងនៃការសិក្សាស្រាវជ្រាវ៖ ភូមិកោះច្បារ និងភូមិចារថ្នោល ស្រុកសំបូរ ខេត្តក្រចេះ

ការស្រាវជ្រាវដែលដឹកនាំដោយសហគមន៍មួយនេះត្រូវបានធ្វើឡើងនៅក្នុងភូមិចំនួនពីរតាមដងទន្លេមេគង្គ ក្នុងស្រុកសំបូរ ខេត្តក្រចេះ។ ភូមិកោះច្បារ មានចម្ងាយ14គីឡូម៉ែត្រពីទីរួមស្រុកសំបូរឡើងទៅខ្សែទឹកខាងលើ ចំណែកភូមិចារថ្នោលស្ថិតនៅចម្ងាយ6គីឡូម៉ែត្រ ចុះទៅខ្សែទឹកប៉ែកខាងក្រោមនៃទីរួមស្រុកសំបូរ (សូមមើលផែនទី)។

## ភូមិកោះច្បារ

គិតត្រឹមដើមឆ្នាំ203 ភូមិនេះមាន237គ្រួសារដែលមានប្រជាជនសរុបចំនួន 1076នាក់ (ស្ត្រី691នាក់)។ ប្រជាជនចំនួនប្រហែលប្រាំមួយភាគរយគឺជាជនជាតិដើមភាគតិចពូនង ចំណែកក្រៅពីនេះគឺជាជនជាតិខ្មែរ។

កាលពីដើម ប្រជាជននៅក្នុងភូមិភាគច្រើនជាអ្នកនេសាទ។ ពួកគាត់ពឹងអាស្រ័យលើធនធានធម្មជាតិដ៏សម្បូរបែបពីព្រៃឈើ និងទន្លេមេគង្គ។ ទឹកទន្លេឡើងចុះទៅតាមរដូវកាល ហើយមានត្រីច្រើន។ ច្រាំងទន្លេសម្បូរដោយដីមានជីជាតិ ដែលអាចឱ្យប្រជាជនដាំដុះបន្លែ និងដំណាំជាច្រើនប្រភេទតាមមាត់ទន្លេ។ ព្រៃឈើក៏ផ្តល់នូវអនុផលជាច្រើនដូចជា ជ័រទឹក (ច្រើនពីដើមដំបង) វល្លិ៍ទឹកឃ្មុំ ជាដើម។ ព្រៃបានផ្តល់ឈើសម្រាប់ធ្វើទូកនិងធ្វើផ្ទះ ហើយក៏ជាប្រភពចំណូលផងដែរ។ ប្រជាជនធ្វើចំការវិលជុំ ដោយដាំដុះស្រូវ និងដំណាំផ្សេងៗ ព្រមទាំងចិញ្ចឹមសត្វដូចជាជ្រូក មាន់ទា គោ និងក្របី។

ប៉ុន្តែ ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ស្ថានភាពទន្លេបានផ្លាស់ប្តូរជាបន្តបន្ទាប់។ ប្រជា-



ទន្លេមេគង្គ, ភូមិកោះច្បារ, 2022។ រូបថត៖ ជឹម ចំរើន



ពាងស្តុកទឹកដែលបូមមកពីទន្លេមេគង្គ, ភូមិកោះច្បារ, 2022។ រូបថត៖ ជឹម ចំរើន

ជនសង្កេតឃើញថាទឹកឡើងចុះមិនទៀងទាត់ បរិមាណត្រីថយចុះ ចំណែកច្រាំងទន្លេបានបាក់ ឬហូរច្រោះដោយទឹក។ ស្ថានភាពនេះបណ្តាលឱ្យអ្នកភូមិមួយចំនួនត្រូវស្វះស្វែងរកមធ្យោបាយផ្សេងទៀតដើម្បីរកប្រាក់ចំណូលឬផ្គត់ផ្គង់ជីវភាព ដូចជាស៊ីឈ្នួលកម្លាំងពលកម្ម ឬធ្វើចំណាកស្រុកទៅកាន់ខេត្ត ឬប្រទេសផ្សេង។

## ភូមិចារថ្នោល

ភូមិចារថ្នោល ស្ថិតនៅខ្សែទឹកខាងក្រោមពីទីរួមស្រុកសំបូរ។ គិតត្រឹមដើមឆ្នាំ2023 ភូមិនេះមាន 206គ្រួសារ ដែលមានប្រជាជនសរុបចំនួន791 នាក់ (ស្ត្រី 476នាក់) ។ ប្រជាជនចំនួនប្រហែលពីរភាគរយគឺជាជនជាតិដើមភាគតិចពូនង ចំណែកក្រៅពីនេះគឺជាជនជាតិខ្មែរ។ ជាប្រពៃណីតាំងពីដើមមក ប្រជាជនភូមិនេះច្រើនរកស៊ីចិញ្ចឹមជីវិតដោយធ្វើស្រែចម្ការ ចិញ្ចឹមសត្វ នេសាទ និងប្រមូលផលអនុផលព្រៃឈើ ដូចជា ជ័រទឹក និងប្រភេទបន្លែព្រៃ ដូចជា ផ្កាចាហួយ ត្រួយរាំង ត្រួយកណ្តោ ស្លឹកព្រិច ស្លឹកច្រេស ស្លឹកកណ្តួបចុងដំបង ជាដើម។ ព្រៃជុំវិញភូមិធ្លាប់មានដើមឈើធំៗជាច្រើនដែលផ្តល់ជាឈើសម្រាប់សាង-សង់ផ្ទះ។

កាលពីដើម ទឹកឡើងឬស្រកទៅតាមធម្មជាតិ និងទៅតាមរដូវកាល។ នៅរដូវប្រាំង កោះខ្សាច់បានផុសឡើង ហើយកន្លែងខ្លះ ទឹកទន្លេមានជម្រៅរាក់ដែលគេអាចដើរឆ្លងបាន។ ថ្មក្នុងទឹកទន្លេមានដុះស្លែ ហើយមានត្រីជាច្រើនមកស៊ីស្លែដែលដុះលើថ្មទាំងនោះ។ ប្រជាជនរកត្រីដោយដាក់មង ស្ទូច ដួស(ប្រលួងត្រី)[1] និងបាចត្រី  ចំណែកអ្នកខ្លះរាវលៀសខ្ចៅខ្យង។

1 ប្រលួងត្រីធ្វើឡើងដោយបាចកន្ទក់ចូលក្នុងទឹក។ នៅពេលត្រីឡើងមកលើផ្ទៃទឹកមកស៊ីកន្ទក់ គេដួសវាជាមួយឧបករណ៍ស្រដៀងនឹងកញ្ច្រែង។



រៀបចំអាហារសម្រាប់ជ្រូកមាន់ទា, ភូមិចារថ្នោល, 2022។ រូបថត៖ ជឹម ចំរើន



ក្របីគឺជាប្រភពចំណូលដ៏សំខាន់សម្រាប់ក្រុមគ្រួសារកសិករ, ភូមិចារថ្នោល, 2022។ រូបថត៖ ជឹម ចំរើន

នៅតាមមាត់ទន្លេ មានដើមឈើជាច្រើនដែលជួយទប់ច្រាំងទន្លេកុំឲ្យបាក់។ ដើមឈើទាំងនេះក៏ផ្តល់ជាទីជម្រកសម្រាប់ត្រី និងក៏ជាកន្លែងត្រីពងផងដែរ។ ដីល្បាប់មានជីជាតិបង្កនូវភាពងាយស្រួលក្នុងការដាំបន្លែ។ ប្រជាជនប្រើទឹកទន្លេ ដើម្បីស្រោចស្រពសួនដំណាំនិងវាលស្រែ ចិញ្ចឹមសត្វ និងប្រើប្រាស់ក្នុងផ្ទះ ដូចជា ចម្អិនអាហារ ងូតទឹក និងបោកខោអាវ ជាដើម។

ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ គេសង្កេតឃើញថា ព្រៃឈើបានបាត់បង់អស់ជាច្រើន ដែលនាំឱ្យអនុផលព្រៃឈើថយចុះ ទិន្នផលត្រីក៏ថយចុះ ចំណែកទន្លេក៏បាក់ច្រាំងដែលនាំឱ្យខូចខាតដល់សួនដំណាំ ដូច្នេះប្រជាជនត្រូវសម្របខ្លួន និងរកមធ្យោបាយចិញ្ចឹមជីវិតនិងបង្កើតប្រាក់ចំណូលផ្សេងទៀត។ ភាគច្រើនគេបានធ្វើចំណាកស្រុកទៅខាងក្រៅស្រុកភូមិដើម្បីស្វែងរកការងារនិងប្រាក់ចំណូល។



ទន្លេមេគង្គ, ភូមិចារថ្នោល, 2022។ រូបថត៖ ជឹម ចំរើន

# 3. គោលបំណង ដំណើរការ និងអ្នកចូលរួម របស់ការស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍

ការស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍នៅភូមិកោះច្បារ និងភូមិចារថ្នោល មានគោលបំណងចងក្រងទុកអំពីការសង្កេត និងបទពិសោធន៍ផ្ទាល់របស់ប្រជាជនក្នុងសហគមន៍ពាក់ព័ន្ធនឹងការផ្លាស់ប្តូររបស់ទន្លេមេគង្គ និងផលប៉ះពាល់ទៅលើជីវភាពរស់នៅរបស់ប្រជាជន។ តាមរយៈដំណើរការនៃការស្រាវជ្រាវ ប្រជាជនបានរៀនសូត្រនិងយល់ដឹងអំពីការប្រែប្រួលរបស់ទន្លេ និងផលប៉ះពាល់របស់វា ហើយក៏បានបង្កើននូវជំនាញនិងភាពជឿជាក់ចំពោះខ្លួនដល់អ្នកស្រាវជ្រាវក្នុងការចងក្រងឯកសារ វិភាគ និងបកស្រាយអំពីការប្រែប្រួលនៅក្នុងសហគមន៍របស់ពួកគាត់។ ការស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍គឺជាជំហានមួយនៅក្នុងដំណើរការស្វែងយល់អំពីបញ្ហាប្រឈមសំខាន់ៗដែលសហគមន៍កំពុងជួបប្រទះ ក្នុងគោលបំណងចែករំលែកព័ត៌មាន និងស្វែងរកវិធានការដឹកនាំដោយសហគមន៍ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះ។

> ខ្ញុំយល់ច្បាស់ជាងមុនអំពីការស្រាវជ្រាវដែលដឹកនាំដោយសហគមន៍។ នៅពេលខ្ញុំចុះសម្ភាសប្រជាជនក្នុងភូមិខ្ញុំ ធ្វើឱ្យខ្ញុំយល់ពីបញ្ហានៃទន្លេរបស់យើងកាន់តែច្បាស់ អំពីការប្រែប្រួលនៃទន្លេរបស់យើង និងផលប៉ះពាល់របស់វា។

> ការសិក្សានេះមានសារៈសំខាន់ណាស់ពីព្រោះវាបានជួយខ្ញុំឱ្យយល់អំពីទន្លេរបស់យើង និងបានជំរុញចិត្តខ្ញុំឱ្យចូលរួមចំណែកអភិរក្ស ថែរក្សាទន្លេរបស់យើង។ ឧទាហរណ៍ យើងអាចជួយសម្អាតវាកុំចោលសំរាមតាមដងទន្លេដើម្បីឱ្យទឹកទន្លេរបស់យើងនៅស្អាតល្អ កុំឱ្យវាកខ្វក់។




ក្រុមការងារស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍ ភូមិកោះច្បារ, 2023។ រូបថត៖ ហែម វណ្ណារ៉េត

“ទន្លេជាសរសៃឈាមរបស់មនុស្ស។ យើងរស់នៅពឹងផ្អែកលើទន្លេដោយផ្ទាល់ និងប្រយោល។ ទន្លេផ្តល់ប្រយោជន៍ច្រើនដល់ក្រុមគ្រួសារនិងសហគមន៍យើងទាំងមូល។ បន្ទាប់ពីខ្ញុំបានយល់ដឹងអំពីគម្រោងអភិវឌ្ឍន៍នានា និងផលប៉ះពាល់របស់វា ការស្រាវជ្រាវដែលដឹកនាំដោយសហគមន៍ បានជំរុញទឹកចិត្តខ្ញុំឱ្យចូលរួមដោះស្រាយបញ្ហាសហគមន៍យើង។ អ្វីដែលសំខាន់គឺយើងគួរសហការរួមគ្នាដោះស្រាយបញ្ហាសហគមន៍ ពីព្រោះបញ្ហាសហគមន៍ប៉ះពាល់យើងទាំងអស់គ្នា។

“ពេលខ្ញុំចូលរួមក្នុងការស្រាវជ្រាវដែលដឹកនាំដោយសហគមន៍នេះ វាបានធ្វើឱ្យខ្ញុំមានការយល់ដឹងច្បាស់អំពីស្ថានភាពសហគមន៍របស់ខ្ញុំ [និង] អត្ថប្រយោជន៍នៃទន្លេរបស់យើង និងផលប៉ះពាល់ដែលបណ្តាលមកពីការផ្លាស់ប្តូរនៃទឹកទន្លេរបស់យើង។ វាបានជួយខ្ញុំឱ្យយល់ច្បាស់អំពីស្ថានភាពពីមុន និងបច្ចុប្បន្ននៃទន្លេរបស់យើង។


ក្រុមការងារស្រាវជ្រាវចុះស្ទាបស្ទង់មតិប្រជាពលរដ្ឋ, ភូមិចារថ្មោល, 2022។ រូបថត៖ ប៊ុន ខេមា


ក្រុមការងារស្រាវជ្រាវ ភូមិចារថ្មោល, 2023។ រូបថត៖ ហែម វណ្ណារ៉េត

## 3.1 ដំណើរការនៃការស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍

ដំណើរការនៃការសិក្សាស្រាវជ្រាវដែលបានធ្វើឡើងនៅកោះច្បារ និងចារថ្មោលអាចបែងចែកជាបួនជំហានធំៗ។

1. **ជំរុញការយល់ដឹង និងចំណាប់អារម្មណ៍អំពីការស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍។** ជំហាននេះរួមទាំងការចែករំលែកព័ត៌មានអំពីការស្រាវជ្រាវ ដំណើរការពាក់ព័ន្ធ និងប្រយោជន៍របស់វា។ អ្វីដែលជាចំណុចសំខាន់គឺសហគមន៍ផ្សេងដែលធ្លាប់បានចូលរួមក្នុងការស្រាវជ្រាវសកម្មភាពសហគមន៍ បានចែករំលែកបទពិសោធន៍អំពីរបៀបធ្វើការស្រាវជ្រាវ និងយកលទ្ធផលទៅផ្សព្វផ្សាយបង្កើនការយល់ដឹង និងស្វែងរកវិធានការដោះស្រាយដែលដឹកនាំដោយសហគមន៍ និងធ្វើផែនការអភិវឌ្ឍន៍ដែលដឹកនាំដោយសហគមន៍។ ការស្តាប់ និងការរៀនសូត្រដោយផ្ទាល់ពីប្រជាជនមកពីសហគមន៍ដទៃ បានធ្វើឱ្យប្រជាជនក្នុងភូមិទាំងពីរមានចំណាប់អារម្មណ៍ និងគាំទ្រដល់ការស្រាវជ្រាវនេះ។


កិច្ចប្រជុំអំពីការស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍ ភូមិកោះច្បារ, 2020។ រូបថត៖ ហែម វណ្ណារ៉េត


ក្រុមការងារស្រាវជ្រាវមកពីសហគមន៍ផ្សេង ចែករំលែកបទ់ពិសោធន៍អំពីការស្រាវជ្រាវសម្រាប់ការអភិវឌ្ឍសហគមន៍និងការការពារធនធានធម្មជាតិ, 2022។ រូបថត៖ ហែម វណ្ណារ៉េត

2. **ស្វែងយល់និងកសាងសមត្ថភាពរបស់សមាជិកក្រុមស្រាវជ្រាវ។** បន្ទាប់ពីបានចូលរួមសិក្ខា-សាលាចែករំលែកព័ត៌មាន ក្រុមដំបូងដែលបានចូលរួមមានមនុស្សដប់នាក់មកពីភូមិទាំងពីរបានស្ម័គ្រចិត្តចូលរួមក្នុងកិច្ចការស្រាវជ្រាវនេះ។ ពួកគាត់បានទទួលការបណ្តុះបណ្តាល និងការគាំទ្រលើវិធីសាស្ត្រ និងឧបករណ៍សម្រាប់រៀបចំដំណើរការស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍។ ក្រោយមក មានអ្នកចូលរួមបន្ថែមទៀតចូលរួម ដោយមានការព្រមព្រៀងពីសំណាក់ប្រជាជនក្នុងភូមិ ដោយមើលទៅលើលក្ខណៈសម្បត្តិដូចជា ភាពជាអ្នកដឹកនាំ ការយល់ដឹងអំពីបញ្ហាប្រឈមក្នុងសហគមន៍ និងសមត្ថភាពចេះអាននិងសរសេរ។ ជាសរុប មានអ្នកចូលរួមចំនួន 29នាក់នៅក្នុងការស្រាវជ្រាវដែលក្នុងនោះ16នាក់មកពីកោះច្បារ និង13នាក់មកពីថារថ្មោល (សូមមើលឧបសម្ពន្ធទី1 បញ្ជីសមាជិកក្រុមការងារស្រាវជ្រាវ)។



ប្រជុំ និងបណ្តុះបណ្តាលសមាជិកក្រុមការងារស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍, 2021-2022។ រូបថត៖ ហែម វណ្ណារ៉េត



សមាជិកក្រុមការងារស្រាវជ្រាវវិភាគអំពីបញ្ហាសហគមន៍ និងកំណត់យកបញ្ហាអាទិភាពសម្រាប់សិក្សា។ រូបថត៖ ហែម វណ្ណារ៉េត

3. **សហការរៀបចំផែនការ និងធ្វើការស្រាវជ្រាវរួមគ្នា។** អ្នកចូលរួមបានធ្វើការវិភាគបញ្ហាសហ-គមន៍ តាមរយៈការពិភាក្សាក្រុម និងការជួបជជែកតាមគ្រួសារ ដើម្បីស្វែងយល់អំពីបញ្ហាសំខាន់ៗ ដើម្បីចងក្រងឯកសារ។ គេបានរៀបចំប្រជុំដើម្បីធ្វើផែនការ សាកល្បង និងកែសម្រួលផែនការនិងកម្រងសំណួរ និងស្វែងរកអ្នកចូល-រួមក្នុងការសិក្សា ដើម្បីឱ្យមានការចូលរួមពីតំណាងនិងសំឡេងមកពីក្រុមមនុស្សចម្រុះ (សូមមើលផ្នែក 3.2 អ្នកចូលរួមក្នុងការស្ទង់មតិអំពីការស្រាវជ្រាវ)។



ក្រុមការងារបច្ចេកទេសសម្របសម្រួលនិងជួយដល់ក្រុមការងារស្រាវជ្រាវសហគមន៍ក្នុងការរៀបចំនិងប្រមូលទិន្នន័យ, ពីឆ្នាំ 2021ដល់2022។ រូបថត៖ ហែម វណ្ណារ៉េត



សហគមន៍ដទៃដែលធ្លាប់ធ្វើកិច្ចការស្រាវជ្រាវពីមុនចែករំលែកបទពិសោធន៍អំពីរបៀបធ្វើការស្រាវជ្រាវ, 2022។ រូបថត៖ ហែម វណ្ណារ៉េត





បណ្តុះបណ្តាលអំពីការវិភាគទិន្នន័យសម្រាប់ក្រុមការងារស្រាវជ្រាវ, 2022។ រូបថត៖ ប៊ុន ខេមា



ប្រជុំចែករំលែកនិងប្រឹក្សាយោបល់អំពីលទ្ធផលនៃការស្រាវជ្រាវ, 2023។ រូបថត៖ ហែម វណ្ណារ៉េត

4. **សហការគ្នាក្នុងការវិភាគទិន្នន័យ និងផ្សព្វផ្សាយលទ្ធផល៖** បន្ទាប់ពីបានប្រមូលនិងរៀបចំទិន្នន័យ និងព័ត៌មានរួច អ្នកចូលរួមនិងទីប្រឹក្សាបានរៀបចំការប្រជុំមួយចំនួនដើម្បីវិភាគទិន្នន័យ និងបង្ហាញលទ្ធផលបឋមដល់ប្រជាជន ហើយពួកគាត់បានផ្តល់មតិកែលម្អមួយចំនួន។ មតិទាំងនោះត្រូវបានយកមករួមបញ្ចូលនៅក្នុងរបាយការណ៍នេះ។ បន្ទាប់មក ការប្រជុំចែករំលែកនិងផ្តល់មតិកែលម្អមួយទៀតជាមួយប្រជាជន អាជ្ញាធរមូលដ្ឋាន និងសមាជិកក្រុមស្រាវជ្រាវ ត្រូវបានគ្រោងទុកនៅក្នុងខែមីនា ឆ្នាំ2023 (សូមមើលតារាងទី1)។



ប្រជុំចែករំលែកនិងប្រឹក្សាយោបល់អំពីលទ្ធផលនៃការស្រាវជ្រាវ, 2023។ រូបថត៖ ប៊ុន ខេមា

### តារាងទី1៖ តារាងពេលវេលានៃសកម្មភាពស្រាវជ្រាវ នៅកោះច្បារ និងចារថ្នោល

| ពេលវេលា | សកម្មភាព |
|---|---|
| 2-4 មីនា 2020<br>13-17 សីហា 2020 | សិក្ខាសាលាចែករំលែកព័ត៌មាននិងពិគ្រោះយោបល់បឋម ដើម្បីបង្កើនការយល់ដឹង និងវាយតម្លៃអំពីចំណាប់អារម្មណ៍ក្នុងការស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍។ |
| ថ្ងៃ3-4 វិច្ឆិកា 2020 | សិក្ខាសាលាចែករំលែកបទពិសោធន៍របស់សហគមន៍ដទៃដែលធ្លាប់បានធ្វើកិច្ចការស្រាវ-ជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍ ចែករំលែកពិសោធន៍អំពីការស្រាវជ្រាវ បញ្ហាប្រឈម និងអត្ថប្រយោជន៍។ ស្វែងរកក្រុមអ្នកស្ម័គ្រចិត្តសហគមន៍ដំបូងចូលរួមក្នុងក្រុមស្រាវជ្រាវ។ |
| មេសា-វិច្ឆិកា 2021 | ក្រុមសមាជិកក្រុមស្រាវជ្រាវពិភាក្សាក្រុមតូចៗ និងជជែកជាមួយបុគ្គម្នាក់ៗ ដើម្បីជូនដំណឹងនិងពិគ្រោះជាមួយសមាជិកសហគមន៍អំពីការស្រាវជ្រាវ និងចំណាប់អារម្មណ៍របស់ពួកគាត់ក្នុងការចូលរួមចំណែកក្នុងដំណើរការស្រាវជ្រាវ។ |
| ថ្ងៃ20-21 ធ្នូ 2021 | រៀបចំវគ្គបណ្តុះបណ្តាលសម្រាប់សមាជិកក្រុមស្រាវជ្រាវ អំពីការស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍ សារៈសំខាន់របស់ការស្រាវជ្រាវ ឧបករណ៍ និងវិធីសាស្រ្តផ្សេងៗសម្រាប់ស្រាវជ្រាវ ដោយផ្តោតសំខាន់លើការវិភាគបញ្ហាសហគមន៍ ដើម្បីស្វែងយល់អំពីបញ្ហាអាទិភាព និងបញ្ហាដែលត្រូវពិនិត្យក្នុងអំឡុងពេលស្រាវជ្រាវ។ រៀបចំដំណើរទស្សន-កិច្ចសហគមន៍ ដើម្បីបង្កើនការយល់ដឹងអំពីទំនាក់ទំនងរវាងការអភិរក្សប្រព័ន្ធអេកូឡូស៊ីសហគមន៍ និងការអភិវឌ្ឍន៍សហគមន៍។ |
| មករា-មីនា 2022 | ពិភាក្សាក្រុម និងជួបជជែកតាមគ្រួសារ ដើម្បីវិភាគបញ្ហាសហគមន៍។ |
| 2-5 មេសា 2022 | ការពិភាក្សារវាងសហគមន៍ និងក្រុមស្រាវជ្រាវ ដើម្បីពិភាក្សាអំពីបញ្ហា និងលទ្ធផលនៃការវិភាគ ដើម្បីស្វែងយល់ និងកំណត់អាទិភាពប្រធានបទដែលត្រូវសិក្សាស្រាវជ្រាវ។ |
| 18-19 មិថុនា 2022 | ការពិភាក្សាក្រុមរវាងសហគមន៍ និងក្រុមស្រាវជ្រាវ អំពីការប្រែប្រួលរបស់ទន្លេ។ |
| 2-4 សីហា 2022 | ទស្សនកិច្ចសិក្សា និងវគ្គបណ្តុះបណ្តាលស្តីពីការស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍។ ទស្សនកិច្ចសិក្សាទៅកាន់សហគមន៍ដែលធ្លាប់បានធ្វើកិច្ចការស្រាវជ្រាវ បានផ្តល់ឱកាសអ្នកអ្នកចូលរួមបានស្តាប់ដោយផ្ទាល់ពីសហគមន៍ផ្សេងអំពីដំណើរការស្រាវជ្រាវ អត្ថប្រយោជន៍ និងបញ្ហាប្រឈម។  ក្រៅពីនេះក៏មានការបណ្តុះបណ្តាលអំពីការប្រមូលទិន្នន័យ ការរៀបចំកម្រងសំណួរ និងគោលការណ៍ "សេរីភាព ការទទួលបានព័ត៌មានជាមុន និងការយល់ព្រម (FPIC)" ។ សមាជិកក្រុមស្រាវជ្រាវបានរៀបចំកម្រងសំណួរដោយមានការគាំទ្រពីអ្នកប្រឹក្សាបច្ចេកទេស និងអ្នកតំណាងមកពីសហគមន៍ដទៃដែលបានធ្វើការស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍។ |
| កញ្ញា 2022 | សមាជិកក្រុមស្រាវជ្រាវសំភាសន៍បុគ្គលពាក់ព័ន្ធ និងសាកល្បងកម្រងសំណួរជាមួយសមា-ជិកក្រុម និងសាច់ញាតិ។ បន្ទាប់មក កម្រងសំណួរត្រូវបានកែសម្រួល និងបញ្ចប់។ |
| ថ្ងៃ7-8 តុលា 2022 | ដំណើរទស្សនៈកិច្ចសហគមន៍ទៅកាន់ខេត្តស្ទឹងត្រែង ដើម្បីស្វែងយល់ពីផលប៉ះពាល់របស់គម្រោងអភិវឌ្ឍន៍ទៅលើ ប្រជាពលរដ្ឋដែលពឹងអាស្រ័យលើទន្លេ និងធនធានធម្មជាតិ។ |
| តុលា-ធ្នូ 2022 | ប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរ និងការសម្ភាសន៍។ វគ្គបណ្តុះបណ្តាលសម្រាប់សមាជិកក្រុមស្រាវជ្រាវអំពីការវិភាគនិងបង្រួបបង្រួមទិន្នន័យ។ បានបង្កើតរបាយការណ៍ព្រាង ជាមួយនឹងលទ្ធផលបឋម ដែលត្រូវបានពិភាក្សាក្នុងចំណោមក្រុមស្រាវជ្រាវ និងសមាជិកសហគមន៍មួយចំនួន។ |
| មករា 2023 | សមាជិកក្រុមស្រាវជ្រាវប្រមូលទិន្នន័យបន្ថែម ដើម្បីបំពេញចន្លោះកង្វះខាតមួយចំនួនដែលបានរកឃើញបង្ហាញតាមរយៈមតិកែលម្អ។ បន្ទាប់មក ក៏បានបង្កើតបានជារបាយការណ៍ព្រាងលើកទី1។ |
| 18-20 កុម្ភៈ 2023 | កិច្ចប្រជុំដើម្បីប្រមូលមតិកែលម្អទៅលើ លទ្ធផលនៃរបាយការណ៍ពង្រាងទី2 ជាមួយសមាជិកសហគមន៍ និងក្រុមការងារស្រាវជ្រាវ។ |
| មីនា 2023 | ចែករំលែករបាយការណ៍ព្រាងទី3និងប្រមូលមតិចុងក្រោយពីសមាជិកសហគមន៍ អាជ្ញាធរមូលដ្ឋាន និងសមាជិកក្រុមស្រាវជ្រាវ។ |



## 3.2 អ្នកចូលរួមក្នុងការស្ទង់មតិអំពីការស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍

ក្រុមការងារស្រាវជ្រាវចង់ឱ្យមានការចូលរួមពីសំឡេងរបស់សមាជិកសហគមន៍ចម្រុះ។ ជាដំបូងក្រុមការងារស្រាវជ្រាវបានដៅក្រុមប្រជាជននានាដោយផ្អែកលើ ជាតិសាសន៍ យេនឌ័រ ស្ថានភាពសង្គម ពិការភាព សាសនា ជីវភាព និងការងារ (ឧ. អ្នកនេសាទ កសិករ មន្ត្រីរដ្ឋាភិបាល ។ល។) ស្ថានភាពគ្រួសារ (ឧ. ចំនួនសមាជិកគ្រួសារ) ជាដើម។

អ្នកចូលរួមសរុបចំនួន103នាក់/គ្រួសារ រួមមានបុរស ស្រ្តី ជនជាតិដើមភាគតិច យុវជន ចាស់ទុំ និងជនដែលមានពិការភាព បានចូលរួមក្នុងការស្ទង់មតិ (សូមមើលតារាងទី2)។ អ្នកចូលរួមស្ទង់មតិតំណាងឱ្យគ្រួសារប្រមាណ 23%នៃគ្រួសារសរុបនៅភូមិកោះច្បារ (55គ្រួសារក្នុងចំណោមគ្រួសារសរុបចំនួន 237) និងភូមិចារថ្នោល (48 គ្រួសារក្នុងចំណោមគ្រួសារសរុបចំនួន 206)។

នៅភូមិកោះច្បារ មានអ្នកឆ្លើយសំណួរចំនួន55នាក់ (ប្រុស28នាក់ ស្រី27នាក់)។ អ្នកឆ្លើយសំណួរចំនួន 49%ជាអ្នកធ្វើស្រែចំការ 20%គឺជាអ្នកនេសាទ និង 5.6% គឺជាអ្នកចិញ្ចឹមសត្វ។ នៅភូមិចារថ្នោលមានអ្នកចូលរួមឆ្លើយសំណួរចំនួន48នាក់ (ប្រុស20នាក់ ស្រី28នាក់)។ អ្នកឆ្លើយសំណួរចំនួន 37.5%គឺជាអ្នកស្រែចំការ  27.1%គឺជាស្ត្រីមេផ្ទះ ហើយ18.8% គឺជាអ្នកនេសាទ។ សូមមើលឧបសម្ពន្ធទី2 អំពីមុខ-របររបស់អ្នកចូលរួមស្ទាបស្ទង់មតិ នៅក្នុងភូមិកោះច្បារ និងភូមិចារថ្នោល។

### តារាងទី2៖ អ្នកចូលរួមក្នុងការស្ទាបស្ទង់មតិ

| ភូមិកោះច្បារ | ចំនួនអ្នកចូលរួមឆ្លើយ | %ធៀបនឹងចំនួនសរុប | ភូមិចារថ្នោល | ចំនួនអ្នកចូលរួមឆ្លើយ | %ធៀបនឹងចំនួនសរុប |
|---|---|---|---|---|---|
| អ្នកចូលរួមសរុប | 55 | | អ្នកចូលរួមសរុប | 48 | |
| បុរស | 28 | 51% | បុរស | 20 | 42% |
| ស្ត្រី | 27 | 49% | ស្ត្រី | 28 | 58% |
| យុវជន/យុវនារី (15-30 ឆ្នាំ) | 9 | 16.5% | យុវជន/យុវនារី (15-30 ឆ្នាំ) | 7 | 14.5% |
| ជនពេញវ័យ (31-59 ឆ្នាំ) | 37 | 67% | ជនពេញវ័យ (31-59 ឆ្នាំ) | 34 | 71% |
| ចាស់ទុំ (60-81 ឆ្នាំ) | 9 | 16.5% | ចាស់ទុំ (60-81 ឆ្នាំ) | 7 | 14.5% |
| ជនដែលមានពិការភាព | 2 | 4% | ជនដែលមានពិការភាព | 2 | 4% |
| ជនជាតិដើមភាគតិច | 3 | 5% | ជនជាតិដើមភាគតិច | 1 | 2% |

# 4. លទ្ធផល៖ ការប្រែប្រួលនៃទន្លេ និងផលប៉ះពាល់ទៅលើជីវភាពរស់នៅរបស់ប្រជាជន

> ការប្រែប្រួលទឹកទន្លេធ្វើឱ្យយើងពិបាករកត្រី ចិញ្ចឹមសត្វ ដាំដាំដំណាំ និង ដងទឹកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ។
>
> អ្នករកត្រី ភេទស្រី អាយុ24ឆ្នាំ ភូមិចារថ្នោល

អ្នកភូមិទាំងអស់នៅកោះច្បារ និងចារថ្នោល ដែលបានចូលរួមក្នុងការស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍ តាមរយៈការស្ទង់មតិ សម្ភាសន៍ និងការពិភាក្សាក្រុមបានលើកឡើងថា ទន្លេមេគង្គឥឡូវនេះខុសពីមុន។ ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក ពួកគាត់សង្កេតឃើញមានការប្រែប្រួលយ៉ាងខ្លាំងទៅលើប្រព័ន្ធអេកូឡូស៊ី និងធនធានរបស់ទន្លេ ដែលពួកគាត់ត្រូវពឹងអាស្រ័យដើម្បីជីវភាពរស់នៅ។ ពួកគាត់ប្រាប់ថា លំហូរទឹក និងកម្រិតទឹកលែងហូរ និងលែងឡើងចុះទៅតាមរដូវ-កាលដូចពីមុនទៀតហើយ។ កាលពីមុនទឹកឡើងក្នុងរដូវវស្សា ហើយស្រកក្នុងរដូវប្រាំង ប៉ុន្តែឥឡូវនេះ ទឹកឡើងឬស្រកមិនទៀងទាត់ និងមិនអាចប៉ាន់ប្រមាណទុកជាមុនបាន ជួនកាលទឹកឡើងខ្លាំង ហើយក៏ស្រកចុះខ្លាំងទៅវិញ។ នៅពេលកំពស់ទឹកប្រែប្រួលមិនទៀងទាត់ ប្រជាជនកត់សម្គាល់ឃើញថា រកត្រីក៏មិនសូវបាន ច្រាំងទន្លេសឹកនិងបាក់ ដែលធ្វើឱ្យបាត់បង់ដីមានជីវជាតិសំរាប់ដាំដំណាំ ចំណែកគុណភាពទឹកក៏មានការប្រែប្រួលដែរ ដែលបានប៉ះពាល់ជាអវិជ្ជមានដល់ជីវភាពរស់នៅរបស់ប្រជាជន។



ទូកចតចោលនៅលើដី បន្ទាប់ពីទឹកស្រកផុត, ភូមិកោះច្បារ, 2023។ ដោយរួមទាំងការថយចុះនូវទិន្នផលត្រីផង អ្នកនេសាទភាគច្រើនបានទុកទូកចោល និងស្វែងរកមុខរបរថ្មី។ រូបថត៖ ម៉ម ពេជ្យ

## 4.1 ការថយចុះបរិមាណត្រី

> ខ្ញុំចាំថា ពេលខ្ញុំមកនៅកោះច្បារដំបូង ក្នុងឆ្នាំ 2007 ខ្ញុំរកត្រីបានគ្រប់គ្រាន់ហូបប្រចាំថ្ងៃ។ ប៉ុន្តែ តាំងពីឆ្នាំ 2012 មក ខ្ញុំរកត្រីលែងសូវបាន។ អញ្ចឹងទើបបានជាខ្ញុំប្ដូរមកដាំបន្លែវិញ។ ខ្ញុំសំណាងដែរ បានអង្គការឱ្យម៉ាស៊ីនបូមទឹកមួយ សម្រាប់បូមទឹកទន្លេស្រោចបន្លែ។
>
> កសិករដាំបន្លែ ភេទស្រី អាយុ55ឆ្នាំ នៅភូមិកោះច្បារ

> ប្រហែល10ឆ្នាំមុន យើងរកត្រីបានច្រើនណាស់។ កូនខ្ញុំទៅរកត្រីតែប៉ុន្មានម៉ោងក៏បានសុទ្ធតែត្រីធំៗ បានយកទៅលក់ផង និងទុកខ្លះសម្រាប់ហូបផង។ ប៉ុន្តែឥឡូវនេះ [ជីវភាព] មិនដូចពីមុនទេ។ រកត្រីអត់សូវបាន សូម្បីតែសម្រាប់ហូបក៏រកមិនសូវបានផង។ ឥឡូវនេះ ទិញត្រីពីផ្សារមកហូបវិញ។ ដល់ពេលរកត្រីមិនសូវបាន កូនប្រុសខ្ញុំឈប់រកត្រី និងបានចេញទៅធ្វើការនៅខេត្តផ្សេងហើយ។
>
> កសិករ ភេទស្រី អាយុ62ឆ្នាំ នៅភូមិកោះច្បារ

> ថ្ងៃខ្លះ រកត្រីសឹងតែមិនបានហូបផង មិនបាច់គិតដល់យកទៅលក់អីទេ។
>
> អ្នកនេសាទ អាយុ53ឆ្នាំ នៅភូមិកោះច្បារ

### បរិមាណត្រីដែលចាប់បានកាលពី10ឆ្នាំមុន ធៀបនឹងបច្ចុប្បន្ន (2012 - 2022)

លទ្ធផលនៃការស្រាវជ្រាវបង្ហាញថា បរិមាណត្រីដែលប្រជាជននៅកោះច្បារ និងចារថ្នោលរកបាន មានការថយចុះខ្លាំងធៀបនឹងកាលពី10ឆ្នាំមុន។ ប្រជាជនបានប្រាប់ថា បរិមាណត្រីដែលចាប់បាន ធ្លាក់ចុះខ្លាំងនៅក្នុងអំឡុង៣ឆ្នាំចុងក្រោយ។ ឧទាហរណ៍ នៅកោះច្បារ កាលពី10ឆ្នាំមុន ប្រជាជនដែលចូលរួមក្នុងការឆ្លើយសំណួរបានប្រាប់ថា ទៅរកត្រីមួយជើងអាចរកបានពី 6ទៅ60គីឡូក្រាម ក្នុងនោះ អ្នកចូលរួមឆ្លើយចំនួន20នាក់ប្រាប់ថា ពួកគាត់អាចរកត្រីបានច្រើនជាង20គីឡូក្រាមក្នុងមួយជើង។ ឥឡូវនេះ ទៅរកត្រីមួយជើងអាចបានច្រើនបំផុត3គីឡូក្រាម។ ភាពខុសគ្នាដ៏ច្រើននេះក៏កើតឡើងដោយសារតែមនុស្សជាច្រើនគាត់ឈប់ធ្វើដំណើរទៅរកត្រីនៅទីឆ្ងាយទៀតហើយ ពីព្រោះពួកគាត់បារម្ភថា ចំណូលមកពីការចាប់ត្រីទប់មិនឈ្នះលើ

ថ្លៃសាំង[1] និងចំណាយផ្សេងៗ។  ដូចគ្នាដែរសម្រាប់អ្នកភូមិចារថ្មោល៖ កាលពី10ឆ្នាំមុន ទៅរកត្រីមួយជើងរកបានពី20 ទៅ100គីឡូក្រាម ប៉ុន្តែឥឡូវនេះ នៅឆ្នាំ2022 អ្នកចូលរួមប្រាប់ថា រកបានច្រើនបំផុតត្រឹម6គីឡូក្រាម (សូមមើលនៅក្នុងឧបសម្ពន្ធ3ក៖ បរិមាណត្រីដែលចាប់បានក្នុងមួយជើង- 10ឆ្នាំមុន និងក្នុងឆ្នាំ2022។

ប្រជាជនប្រាប់ថា ពួកគាត់បានបន្ថែមឧបករណ៍ចាប់ត្រីរបស់គាត់ទ្វេដង ប៉ុន្តែនៅតែចាប់ត្រីបានតិចជាងមុន។

គួរកត់សម្គាល់ផងដែរថា អ្នករកត្រីមានពីរប្រភេទ៖ 1) អ្នកដែលធ្វើដំណើរឆ្ងាយពីផ្ទះរយៈពេលពីរបីថ្ងៃ ពេលត្រឡប់មកវិញពួកគាត់អាចរកត្រីបានច្រើន។ អ្នកចូលរួមឆ្លើយម្នាក់បានប្រាប់ថាគាត់ធ្លាប់រកបានរហូតដល់ 100គីឡូក្រាម។ 2) អ្នករកត្រីក្បែរផ្ទះ រយៈពេលកន្លះថ្ងៃ ឬក៏អ្នករកដោយដាក់មង ឬឧបករណ៍ផ្សេងៗ ទុកចោលមួយយប់ រួចទៅសា ឬបម្រុលត្រីនៅព្រឹកបន្ទាប់។ ជាធម្មតា ពួកគាត់ធ្លាប់រកត្រីបានដល់10គីឡូក្រាម។

## ទំហំត្រីដែលរកបាន

ប្រជាជនក៏បានប្រាប់ផងដែរថា ទំហំត្រីដែលគាត់រកបានកាន់តែតូចទៅៗ បើធៀបនឹងដប់ឆ្នាំមុន។ បើនិយាយអំពីទំហំត្រី គេចែកត្រីចេញជាពីរប្រភេទគឺ ត្រីធំ និងត្រីតូច។

> កាលពីមុន ត្រី... យើងគ្រាន់តែប្រលួងវាបន្តិច... វាហក់ឡើងមកលើទឹកយ៉ាងប្រសាច ហើយយើងជួសទៅ ក៏បានត្រីគរគោគ(ច្រើន)។[3]
>
> កសិករ ភេទស្រី អាយុ43ឆ្នាំ
> នៅភូមិកោះច្បារ

ប្រភេទត្រីធំមានដូចជា ត្រីសណ្តាយ ត្រីក្អែក ត្រីត្រសក់ ត្រីផ្ទក់ ត្រីប្រា ត្រីក្អី។ កាលពី10ឆ្នាំមុន ប្រជាជនអាចរកបានត្រីទាំងនោះ ដែលត្រីមួយអាចមានទម្ងន់ចន្លោះពី10ទៅ15គីឡូក្រាម ប៉ុន្តែឥឡូវនេះ ត្រីធំមួយបានទម្ងន់យ៉ាងច្រើនត្រឹម3គីឡូ។

ពពួកត្រីតូចមានដូចជា ត្រីរៀល ត្រីចង្វា ត្រីស្លឹកឬស្សី ត្រីកញ្ចុះ ត្រីក្អិត ត្រីប្រកែង ត្រីគល់ព្រិច ត្រីកំភ្លៀញ។ ទំហំត្រីតូចឥឡូវក៏កាន់តែតូចជាងមុនដែរ។ ប្រជាជនរាយការណ៍ថា កាលពី10ឆ្នាំមុន ត្រីប្រកែង ឬត្រីគល់ព្រិចមួយ ពេលខ្លះអាចមានទម្ងន់រហូតដល់ទៅ 3ខាំ ឬ កន្លះគីឡូ ប៉ុន្តែសព្វថ្ងៃសម្រាប់ត្រីទាំងពីរនេះ គេចាប់បានមួយយ៉ាងច្រើនមានទម្ងន់ពី 2ខាំ ឬ 3ខាំ។

អ្នកភូមិកោះច្បារលើកឡើងថា កាលពីមុន ពួកគាត់មិនហូបត្រីតូចទេ។ ប៉ុន្តែឥឡូវ សូម្បីតែត្រីតូចក៏រកស្ទើរតែមិនបានផង។ ឥឡូវ ពួកគាត់ច្រើនទិញត្រីចិញ្ចឹមមកហូប។

2 អ្នកភូមិកោះច្បារខ្លះធ្វើដំណើរចេញពីផ្ទះពីរបីយប់ ចំណាយថ្លៃសាំងប្រហែល3-4លីត្រ ចំណែកអ្នកភូមិចារថ្មោលច្រើនចេញដំណើរនៅម៉ោងប្រហែលបីរសៀល និងត្រឡប់មកវិញប្រហែលម៉ោងប្រាំព្រឹក ដោយចំណាយសាំងអស់2-3លីត្រ។

3 ប្រលួងត្រីធ្វើឡើងដោយបាចកន្ទក់ចូលក្នុងទឹក។ នៅពេលត្រីឡើងមកលើផ្ទៃទឹកមកស៊ីកន្ទក់ គេជួសវាជាមួយឧបករណ៍ស្រដៀងនឹងកញ្ច្រែង។



## ពូជត្រី

ធៀបនឹងដប់ឆ្នាំមុន ពូជត្រីឥឡូវនេះក៏មានតិចជាងមុនដែរ។ នៅក្នុងភូមិកោះច្បារ ប្រជាជនដែលចូល-រួមក្នុងការស្រាវជ្រាវបានរកឃើញពូជត្រីចំនួន31ប្រភេទ ចំណែកភូមិចារថ្មោល មាន14ប្រភេទ (សូមមើលឧបសម្ពន្ធ 3ក៖ ពូជត្រីដែលគេច្រើនរកបានក្នុងឆ្នាំ2022)។ ប្រភេទត្រីទាំងនេះតិចជាងកាលពីដប់ឆ្នាំមុន។ ចម្លើយរបស់អ្នកចូលរួមក្នុងការស្រាវជ្រាវបញ្ជាក់ឱ្យឃើញថា នៅកោះច្បារ ពូជត្រីដែលកម្ររកបានមានប្រហែល 17ប្រភេទ ចំណែកនៅចារថ្មោល មានប្រហែល 35ប្រភេទ ដែលគេកម្ររកបាន នៅឆ្នាំ2022 (សូមមើលឧបសម្ពន្ធទី 3គ៖ ពូជត្រីកម្ររកបាននៅឆ្នាំ2022)។ កាលពី10ឆ្នាំមុន ពពួកត្រីទាំងនេះត្រូវគេរកបានជាញឹកញាប់ សម្រាប់ហូបក្នុងគ្រួសារ ចែករំលែកជាមួយអ្នកជិតខាងនិងបងប្អូន និងលក់នៅផ្សារ។ អ្នកចូលរួមឆ្លើយសំណួរក៏បានបញ្ជាក់ផងដែរអំពីប្រភេទត្រីមួយចំនួនដែលលែងឃើញមាន ឬរកមិនបានទាល់តែសោះក្នុងឆ្នាំ2022 (សូមមើលឧបសម្ពន្ធ 3ឃ៖ ពូជត្រីដែលលែងឃើញមាន ឬរកមិនបាននៅឆ្នាំ2022)។



ត្រីដាក់លក់នៅផ្សារក្នុងទីរួមខេត្តក្រចេះ, 2023។ រូបថត៖ ហែម វណ្ណារ៉េត



ត្រីដែលអ្នកភូមិរកបានមានបរិមាណថយចុះ ចំណែកទំហំត្រីក៏តូចៗ, ភូមិកោះច្បារ, 2022។ រូបថត៖ ជឹម ចំរើន

## 4.2 កសិកម្ម និងការចិញ្ចឹមសត្វតាមមាត់ទន្លេ

> ខ្ញុំឈប់ដាំដំណាំតាមច្រាំងទន្លេហើយ ព្រោះច្រាំងទន្លេឥឡូវវាចោតខ្លាំងពេក ធ្វើឱ្យខ្ញុំពិបាកចុះទៅដងទឹកពីទន្លេ មកស្រោចដំណាំ។ ឥឡូវខ្ញុំទិញទឹក (ទឹកម៉ាស៊ីន) មកប្រើ តែមិនហ៊ានប្រើវាមកស្រោចដំណាំនោះទេ ព្រោះទឹកម៉ាស៊ីននេះវាថ្លៃ។
>
> កសិករ ភេទប្រុស អាយុ52ឆ្នាំ
> នៅភូមិចារថ្នោល

### កសិកម្មតាមដងទន្លេ

ក្នុងភូមិកោះច្បារ និងភូមិចារថ្នោល ច្រាំងទន្លេមេគង្គសំបូរជីជាតិ ដែលជាប្រភពអាហារដ៏សំខាន់ និងអាចរកចំណូលបានបន្ថែម។ ប្រជាជននៅក្នុងភូមិទាំងពីរបានដាំបន្លែនិងផ្លែឈើចម្រុះនៅតាមមាត់ទន្លេ មានដូចជា ផ្ទី ត្រកួន ត្រសក់ ននោង ប្រពាយ ម្ទេស ជី ត្រឡាច សណ្ដែកវែង ប៉េងប៉ោះ ត្រប់ ល្ពៅ ពោត ត្រាវ ដំឡូងផ្វាឱឡឹក សណ្ដែកបែតង លីងលាក់ ល្ហុង ត្រសក់ស្រូវ សាឡាត់ និងឃ្លោក ជាដើម។ ប្រជាជនភាគច្រើនបាននិយាយថា ពួកគាត់ដាំដំណាំទាំងនេះសម្រាប់ហូបក្នុងគ្រួសារ និងចែកឱ្យជាមួយអ្នកជិតខាងនិងបងប្អូន។ អ្នកខ្លះយកទៅលក់ ដើម្បីរកប្រាក់ចំណូលបន្ថែម។ ប៉ុន្តែ ឥឡូវនេះប្រជាជនជាច្រើនបានឈប់ដាំដំណាំទាំងនេះហើយ ដោយសារតែការប្រែប្រួលនៃទន្លេ និងច្រាំងទន្លេ។

ប្រជាជនដែលចូលរួមឆ្លើយសំណួរទាំងអស់ ដែលធ្វើកសិកម្មតាមមាត់ទន្លេបានកត់សម្គាល់ថា ការប្រែប្រួលរបស់ទន្លេមានផលប៉ះពាល់ជាខ្លាំងទៅលើលទ្ធភាពដាំដុះនៅតាមមាត់ទន្លេ។ ដូចមានបង្ហាញនៅក្នុងឃ្លាដកស្រង់សម្ដីរបស់ពួកគាត់ ផលប៉ះពាល់សំខាន់ៗរួមមាន៖ ការបាក់ច្រាំងទន្លេ ដែលធ្វើឱ្យច្រាំងខ្លះចោតពេកមិនអាចដាំបន្លែបាន ពិបាកចុះទៅប្រើប្រាស់ឬដងទឹក បាត់បង់ជីវជាតិដី កម្រិតទឹកឡើងឬស្រកមិនអាចប៉ាន់ស្មានបាន ដែលបង្កឱ្យជន់លិចឬខូចខាតដំណាំតាមមាត់ទន្លេក្នុងរដូវប្រាំង។ ការបាត់បង់លទ្ធភាពដាំដុះតាមមាត់ទន្លេ បានធ្វើឱ្យបាត់បង់ប្រភពអាហារ និងប្រាក់ចំណូលរបស់អ្នកភូមិនៅកោះច្បារ និងចារថ្នោល។

គ្រួសារខ្លះបានឈប់ដាំដំណាំតាមមាត់ទន្លេ ដោយសារសមាជិកគ្រួសាររបស់ពួកគាត់ធ្វើចំណាកស្រុក ដើម្បីស៊ីឈ្នួលពលកម្ម ឬរកឱកាសបង្កើតប្រាក់-ចំណូលផ្សេងៗ។ ជាធម្មតា អ្នកដែលធ្វើចំណាកស្រុកគឺជាអ្នកដែលមានកម្លាំងក្នុងមើលថែច្បារដំណាំតាមមាត់ទន្លេ ដែលត្រូវការនូវកម្មាំងពលកម្មក្នុងការរៀបចំ និងថែទាំ ដូចជាធ្វើរបងការពារដើម្បីកុំឱ្យសត្វពាហនៈចូល និងស្រោចទឹកជាប្រចាំ។ សមាជិកគ្រួសារដែលនៅផ្ទះច្រើនតែមានវ័យចំណាស់ ដែលពួកគាត់គ្មានកម្លាំងថែទាំច្បារដំណាំទេ។ ពួកគាត់ត្រូវពឹងផ្អែកលើប្រាក់ដែលកូនចៅគាត់ដែលធ្វើចំណាកស្រុក ជាអ្នកផ្ញើឱ្យដើម្បីទិញបន្លែ។


សួនដំណាំតាមមាត់ទន្លេ, 2021។ រូបថត៖ ហែម វណ្ណារ៉េត


ការសឹករេចរឹលបាក់ដីមាត់ទន្លេបង្កឱ្យបាត់បង់ដីសម្រាប់ដាំសួនដំណាំតាមមាត់ទន្លេ។ អ្នកភូមិខ្លះមានសួននៅឆ្ងាយពីមាត់ទន្លេ ប៉ុន្តែពិបាកក្នុងការបូមទឹកទៅស្រោចស្រព, 2021។ រូបថត៖ ហែម វណ្ណារ៉េត

> ការប្រែប្រួលរបស់ទន្លេ បានធ្វើឲ្យដីដែលធ្លាប់តែមានជីជាតិ លែងមានជីជាតិ ដាំដំណាំមិនសូវបាន ពីព្រោះឥឡូវនេះដាំអ្វីក៏មិនកើតដែរ។ លែងសូវចេញផ្លែផ្កាដូចពីមុនទៀតហើយ។ ឥឡូវ យើងអត់សូវមានបន្លែធម្មជាតិហូបទេ គេនាំគ្នាដាក់ជីគីមីដើម្បីឱ្យដីមានជីជាតិ។
>
> អ្នករកត្រី ភេទប្រុស អាយុ40ឆ្នាំ
> នៅភូមិចារថ្នោល

> បើនិយាយទៅ ទឹកទន្លេឥឡូវវាច្រើនតែហូររាងលឿន និងខ្លាំង។ ពេលដែលទឹកហូរខ្លាំង វាក៏ហូរយកដីល្បាប់ទៅអស់។ ហើយ ពេលទឹកស្រក ដីក៏ឆាប់ស្ងួតនិងពិបាកក្នុងការដាំដុះ។ ពេលយើងដាំដំណាំជិតបានផលហើយ ទឹកក៏ឡើងខុសរដូវ នាំឱ្យងាប់រលួយដំណាំយើងដែលខំដាំអស់។
>
> កសិករដាំបន្លែ អាយុ52ឆ្នាំ
> នៅភូមិចារថ្នោល

> ពេលទឹកទន្លេឡើង ដំណាំបន្លែរលួយងាប់អស់ តែពេលទឹកស្រក ទឹកទន្លេក៏ស្រកទៅឆ្ងាយពីច្រាំងទន្លេ ពិបាកទៅដងទឹកមកស្រោចដំណាំ។
>
> បុរសកសិករ ជនជាតិដើមភាគតិច
> នៅភូមិកោះច្បារ

> ទឹកទន្លេប្រែប្រួលមិនទៀងទាត់ អញ្ចឹងយើងពិបាកដាំដុះ ដាំអីក៏មិនសូវកើត។
>
> កសិករ ភេទប្រុស អាយុ45ឆ្នាំ
> នៅភូមិកោះច្បារ

> ឥឡូវលែងមានច្រាំងទន្លេសម្រាប់ដាំដំណាំទៀតហើយ។
>
> ស្ត្រីវ័យ60ឆ្នាំ អ្នកដាំបន្លែ
> នៅភូមិចារថ្នោល


ការសឹករេចរឹល និងបាក់ដីមាត់ទន្លេ, 2023។
រូបថត៖ ម៉ម ពេជ្យ

## ការចិញ្ចឹមសត្វ

ប្រជាជនដែលចូលរួមឆ្លើយសំណួរស្ទង់មតិទាំងអស់ដែលចិញ្ចឹមសត្វ បានប្រាប់ថា ការប្រែប្រួលរបស់ទន្លេ ជាពិសេសកម្រិតទឹកមិនទៀងទាត់ និងការថយចុះគុណភាពទឹក មានផលប៉ះពាល់ដល់ការចិញ្ចឹមសត្វតាមដងទន្លេ។ ប្រជាជនប្រាប់ថា ក្របីខ្លះហើមពោះ ដោយសារផឹកទឹកទន្លេ ជួនកាលក្របីអាចស្លាប់ក៏មាន។ ទឹកឡើងឬស្រកមិនទៀងទាត់ ក៏ធ្វើឱ្យខូចខាតរុក្ខជាតិ ដែលនាំឱ្យសត្វខ្វះចំណីស៊ី។ ហើយពេលខ្លះ ទឹកឡើងមកជន់លិចទ្រុងសត្វអស់។


ក្របីសំរាកនៅមាត់ទន្លេមេគង្គ, ភូមិកោះច្បារ, 2023។
រូបថត៖ ម៉ម ពេជ្យ

> នៅពេលដែលទឹកឡើង ជ្រូក មាន់ទា ឆាប់ឈឺ រាករូស ហើមពោះ ឬងាយឈឺច្រើន។ ពេលទឹកឡើង គោក្របីស៊ីស្មៅដែលទឹកលិច ហើយក៏វាទៅជាឈឺ។
>
> កសិករ ភេទស្រី អាយុ40ឆ្នាំ នៅភូមិចារថ្នោល

> សត្វឆាប់ឈឺណាស់ នៅពេលទឹកឡើង វាអាចងាយនឹងងាប់។ ពេលសត្វដែលយើងចិញ្ចឹមងាប់ យើងខាតលុយ អត់មានចំណូល ជីវភាពក៏កាន់តែយ៉ាប់យឺន។
>
> កសិករ ភេទប្រុស អាយុ70ឆ្នាំ
> នៅភូមិកោះច្បារ


ការចិញ្ចឹមសត្វគឺជាប្រភពប្រាក់ចំណូលដ៏សំខាន់មួយ,
ភូមិ ចារថ្នោល, 2023។ រូបថត៖ ជឹម ចំរើន

## 4.3 ការថយចុះគុណភាពទឹក

ទន្លេមេគង្គនៅតែជាប្រភពទឹកដ៏សំខាន់សម្រាប់អ្នកភូមិកោះច្បារ ដែលគ្មានទឹកម៉ាស៊ីនប្រើប្រាស់។ ប្រជាជនដែលបានចូលរួមឆ្លើយសំណួរទាំងអស់និយាយថា ពួកគាត់ប្រើប្រាស់ទឹកទន្លេជារៀងរាល់ថ្ងៃ។ អ្នកភូមិចារថ្នោលដែលបានចូលរួមឆ្លើយចំនួន 77% ដែលមានទឹកម៉ាស៊ីនប្រើហើយ ក៏នៅតែបន្តប្រើទឹកទន្លេជារៀងរាល់ថ្ងៃដែរ។ ប្រជាជនភាគច្រើននៅភូមិចារថ្នោល នៅតែប្រើទឹកទន្លេមេគង្គសម្រាប់ធ្វើស្រែចម្ការ ឬចិញ្ចឹមសត្វ ពីព្រោះទឹកម៉ាស៊ីនមានតម្លៃថ្លៃ។ ក៏ប៉ុន្តែ ទឹកទន្លេមានការប្រែប្រួល ដោយគុណភាពទឹកបានធ្លាក់ចុះ។ ប្រជាជនប្រាប់ថា មានស្លែ ពពុះ និងសំរាមនៅក្នុងទឹក ច្រើនជាងពីមុន។ ប្រជាជនខ្លះបាននិយាយថា ទឹកឥឡូវនេះមានក្លិនឆ្អាប ឬក្លិនភក់ មានសភាពល្អក់កករច្រើន និងមិនអាចហូបបាន។

ឃ្លាស្រង់ពាក្យសំដីរបស់ប្រជាជនដែលមាននៅទីនេះបង្ហាញឱ្យឃើញពីការធ្លាក់ចុះនៃគុណភាពទឹក និងផលប៉ះពាល់ដល់សុខភាព។ ពួកគាត់បានកត់សម្គាល់ឃើញថា ទឹកទន្លេធ្វើឱ្យអ្នកខ្លះឡើងរមាស់ (សម្រាប់អ្នកដែលមានស្បែកឆាប់ប្រតិកម្ម) ឈឺពោះ និងរាគរូស។

> ខ្ញុំឈប់ប្រើទឹកទន្លេទៀតហើយ ព្រោះវាល្អក់ មើលទៅកខ្វក់ កករ ដូចមានដីច្រើន។ ខ្ញុំទិញទឹកម៉ាស៊ីនសម្រាប់ប្រើប្រាស់ក្នុងផ្ទះ។ បើនិយាយទៅ ពេលខ្ញុំងូតទឹកទន្លេ វាងាយធ្វើឱ្យស្បែករមាស់។
>
> ស្ត្រីមេផ្ទះ អាយុ40ឆ្នាំ នៅភូមិចារថ្នោល

> ខ្ញុំប្រើទឹកទន្លេសម្រាប់តែបោកខោអាវទេ អត់ប្រើសម្រាប់ធ្វើម្ហូបឬផឹកទេ។ ក្មេងៗឥឡូវ ម៉ែឪអត់សូវឱ្យទៅលេងទឹកទន្លេទេ ព្រោះខ្លាចឈឺ រាគរូស ដោយសារទឹកវាអត់សូវស្អាត។ បើនិយាយទៅ សុខភាពយើងងាយឈឺ ដោយសារទឹកអត់សូវស្អាត។
>
> អ្នកនេសាទ ភេទប្រុស អាយុ40ឆ្នាំ
> នៅភូមិកោះច្បារ

> ឥឡូវ ប្រជាជនខ្លះគាត់ទិញទឹកសម្រាប់ប្រើប្រាស់ក្នុងផ្ទះ ដូច្នេះគាត់ត្រូវខំប្រឹងរកលុយដើម្បីទប់ទល់ការចំណាយ។ ដូច្នេះអ្នកខ្លះ គាត់ត្រូវធ្វើចំណាកស្រុកដើម្បីស្វែងរកប្រាក់ចំណូល។ ហើយក្មេងៗខ្លះ មានច្រើនដែរ គាត់បានឈប់រៀន ដោយសារតែទៅតាមម៉ែឪ។
>
> កសិករស្ត្រី អាយុ56ឆ្នាំ នៅភូមិចារថ្នោល

> ពីមុន យើងអាចផឹកទឹកទន្លេដោយមិនចាំបាច់ដាំក៏បាន ប៉ុន្តែឥឡូវនេះ យើងអត់អាចផឹកទឹកអត់ដាំបានទៀតទេ។
>
> កសិករ ភេទស្រី អាយុ54ឆ្នាំ


ទន្លេមេគង្គ, ភូមិកោះច្បារ, 2022។ រូបថត៖ ជឹម ចំរើន

នៅភូមិចារថ្មោល ប្រជាជនមួយចំនួនឈប់ប្រើទឹកទន្លេមេគង្គសម្រាប់ផឹកនិងធ្វើម្ហូបទៀតហើយ។ ពួកគាត់ត្រូវចំណាយលុយទិញទឹក ដែលការចំណាយនេះបានបន្ថែមបន្ទុកគ្រួសារដែលកំពុងប្រឈមមុខនឹងការកើនឡើងនៃថ្លៃចំណាយសម្រាប់តម្រូវការប្រចាំថ្ងៃផង និងការបាត់បង់ប្រាក់ចំណូលដោយសារការធ្លាក់ចុះនូវបរិមាណត្រី និងការបាត់បង់សួនដំណាំតាមមាត់ទន្លេផង។

> “ឥឡូវ គ្រួសារខ្ញុំអត់រស់នៅជាមួយគ្នាដូចពីមុនទេ។ កូនស្រីខ្ញុំទៅធ្វើការនៅខេត្តផ្សេងដើម្បីរកប្រាក់។ ព្រោះឥឡូវយើងរកត្រីមិនសូវបាន ហើយព្រៃឈើក៏អស់។ ពីមុន យើងអាចរកត្រីបានសំរាប់ចិញ្ចឹមជីវិត ដោះស្រាយជីវភាពបាន តែឥឡូវរកត្រីអត់សូវបាន ជីវភាពក៏ខ្វះខាត។ ពេលខ្លះ រកត្រីតែសម្រាប់ហូបខ្លួនឯងក៏មិនគ្រប់ផង មិនចាំបាច់និយាយដល់ទៅការរកត្រីសំរាប់លក់ដូរអីទេ។
>
> អ្នកនេសាទ ភេទស្រី អាយុ34ឆ្នាំ
> នៅភូមិកោះច្បារ

> “ពីមុន យើងមិនសូវខ្វល់ពីជីវភាពប្រចាំថ្ងៃទេ ព្រោះយើងអាចដាក់មងទុកចោលចោលពីរបីម៉ោង ឬចំណាយពេលរកត្រីពីកន្លះម៉ោងទៅ១ម៉ោងមួយថ្ងៃ ក៏អាចរកត្រីបានគ្រប់គ្រាន់សម្រាប់ធ្វើម្ហូបដែរ។ ថ្ងៃ ប៉ុន្តែឥឡូវ រកត្រីមិនបានទេ ចេះតែព្រួយចិត្តថា ថ្ងៃនេះហូបអីហើយស្អែកមិនដឹងបានអីហូប។ អ្នកខ្លះខ្ចីលុយអង្គការ [មីក្រូហិរញ្ញវត្ថុ] បើករបររកស៊ីលក់ដូរ។ អ្នកខ្លះគាត់រកស៊ីមិនចំណេញ ក៏ធ្វើចំណាកស្រុកទៅដើម្បីរកលុយសងបំណុលគេ។ អ្នកខ្លះក៏លក់ដី យកលុយសងបំណុលគេ។
>
> កសិករ ភេទស្រី អាយុ45ឆ្នាំ នៅភូមិកោះច្បារ

## 4.4 ការប្រែប្រួល និងផលប៉ះពាល់ផ្សេងទៀតដែលបានរកឃើញក្នុងពេលសិក្សាស្រាវជ្រាវ

### បំណុល

ដោយសារការថយចុះនៃធនធានធម្មជាតិ ជាពិសេសត្រី ដែលជាស្បៀងដ៏សំខាន់ ប្រជាជនបានស្វែងរកមធ្យោបាយចិញ្ចឹមជីវិតផ្សេងទៀត ដើម្បីរកចំណូលទិញអាហារសម្រាប់ក្រុមគ្រួសាររបស់ពួកគាត់។ ប្រជាជនខ្លះខ្ចីលុយមីក្រូហិរញ្ញវត្ថុដើម្បីបើកមុខរបររកស៊ី។ ប៉ុន្តែ មុខរបរខ្លះមិនអាចរកប្រាក់ចំណូលបានគ្រប់គ្រាន់ ដូច្នេះ ពួកគាត់ត្រូវធ្វើចំណាកស្រុកទៅកាន់ស្រុកផ្សេងដើម្បីស្វែងរកប្រាក់មកសងបំណុលគេ។ នៅក្នុងឃ្លាដកស្រង់សំដីខាងក្រោមបង្ហាញថា ប្រជាជនខ្លះត្រូវបង្ខំចិត្តលក់ដីដើម្បីសងបំណុលគេ។



ស្ត្រីម្នាក់ដោះត្រីចេញពីមងរបស់គាត់, ភូមិកោះច្បារ, 2021។ គាត់និយាយដោយបារម្ភថា រកត្រីមិនសូវបានប៉ះពាល់ខ្លាំងដល់ជីវភាពរបស់គាត់។ រូបថត៖ ហែម វណ្ណារ៉េត





សាលាសន្សំបុណ្យ ភូមិចារថ្មោល, 2023។ រូបថត៖ ជឹម ចំរើន

> “សាលាបុណ្យភូមិយើងឥឡូវកំពុងមានបញ្ហាដោយសារដីមាត់ទន្លេមិនរឹងមាំដូចពីមុនទេ វារាងដូចជាផុសៗ ដីនៅខាងក្រោមសាលាបុណ្យហ្នឹង មើលទៅមានប្រហោងខូងមួយ (អ្នកភូមិខ្លះ គេថាវាជារូងនាគ តែអ្នកខ្លះថាវាជាការហូរច្រោះដី)។ បើនិយាយទៅ គ្រឹះសាលាបុណ្យបានទ្រុឌទ្រោមដោយសារដីអត់សូវមាំដូចមុន។ ប្រជាជនបានរៃលុយគ្នាទិញដីចាក់ទប់គ្រឹះសាលាបុណ្យហើយ ប៉ុន្តែទៅថ្ងៃមុខ យើងមិនដឹងថាវាអាចនៅបានយូរប៉ុន្មានទេ ពីព្រោះយើងឃើញរូងនៅពីក្រោមសាលាបុណ្យនោះ។ កាលពីមុន យើងមានដើមឈើធំៗនៅតាមច្រាំងទន្លេ ប៉ុន្តែឥឡូវដើមឈើធំៗខ្លះមួយចំនួនធំបានបាក់អស់ហើយព្រោះទឹកហូរលឿនពេក ហើយច្រាំងទន្លេក៏បាក់ នាំឱ្យដើមឈើនោះរលំទៅជាមួយ។
>
> កសិករ ភេទស្រី អាយុ55ឆ្នាំ នៅភូមិចារថ្មោល

### ការសឹករេចរឹលច្រាំងទន្លេអាចប៉ះពាល់ដល់សាលាសន្សំបុណ្យសហគមន៍

សាលាសន្សំបុណ្យ[4] ភូមិចារថ្មោល មានទីតាំងនៅក្បែរមាត់ទន្លេ។ ការរេចរឹលច្រាំងទន្លេ បណ្ដាលឱ្យដីបាក់ស្រុត នៅក្នុងបរិវេណសាលាបុណ្យ ធ្វើឱ្យសំណង់សាលាបុណ្យស្រុត។ អ្នកភូមិចារថ្មោល បានបរិច្ចាគថវិកាដើម្បីទិញដីចាក់ដីបំពេញ ដើម្បីការពារកុំឱ្យមានការស្រុតបន្តទៀត ប៉ុន្តែគេមិនដឹងថាតើវានឹងអាចទប់ទល់ជាមួយនឹងសំណឹកច្រាំងទន្លេបានយូរប៉ុណ្ណានោះទេ។

### ការប្រែប្រួលរបស់ទន្លេបណ្ដាលឱ្យស្ត្រីនិងកុមារទទួលរងផលប៉ះពាល់មិនសមាមាត្រគ្នា

ការប្រែប្រួលទឹកទន្លេធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពទទួលបានអាហារ ដូចជាត្រី និងសួនដំណាំ ដែលជាប្រភព

4 សាលាសន្សំបុណ្យ គឺជាសាលាឆទានសហគមន៍ ប្រើប្រាស់ជាទូទៅសម្រាប់សកម្មភាពឬប្រយោជន៍សហគមន៍ ឬប្រារព្ធពិធីបុណ្យទានផ្សេងៗ

ប្រាក់ចំណូល។ ចំណែកការខូចបង់គុណភាពទឹកក៏បានប៉ះពាល់ខ្លាំងដែរទៅលើស្ត្រី និងកុមារ ក្នុងកម្រិតដែលមិនសមមាត្រធៀបនឹងក្រុមដទៃ។ ស្ត្រីភាគច្រើនគឺជាអ្នកដងទឹកនិងប្រើទឹកពីទន្លេ សម្រាប់កិច្ចការក្នុងគ្រួសារ។ ការសឹករេចរឹលច្រាំងទន្លេធ្វើឲ្យច្រាំងចោត ដែលធ្វើឲ្យស្ត្រីពិបាកចុះទៅដងឬប្រើទឹក។ ការខូចគុណភាពទឹកក៏ប៉ះពាល់ដល់សុខភាពស្ត្រី និងកុមារផងដែរ។ ប្រជាជនមួយចំនួនប្រាប់ថាកុមារមានជំងឺឈឺថ្កាត់ដោយសារទឹក។ បរិមាណជលផលថយចុះ និងការខូចបង់សួនដំណាំតាមមាត់ទន្លេបណ្ដាលឱ្យមានការថយចុះនូវបរិមាណអាហារសម្រាប់ផ្គត់ផ្គង់គ្រួសារ។ ស្ត្រីខ្លះត្រូវធ្វើចំណាកស្រុកទៅខេត្តផ្សេងដើម្បីរកការងារធ្វើ ពេលខ្លះ ត្រូវនាំទាំងកូនទៅជាមួយផង ដែលបណ្ដាលឱ្យកូនត្រូវឈប់រៀន ដើម្បីទៅតាមម្ដាយ។

## ការកើនឡើងនៃស្លែប្រភេទថ្មីនៅក្នុងទន្លេ

អ្នកភូមិកោះច្បារ និងចារថ្មោលនិយាយថា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះមានឃើញដុះស្លែប្រភេទថ្មី។ កាលពីមុន ស្លែដុះនៅលើថ្មក្នុងទន្លេ និងមានប្រវែងវែង។ ឥឡូវ ស្លែមានលក្ខណៈខ្លីៗដុំៗ និងមានក្លិនភក់ហើយអ្នកភូមិប្រាប់ថា ត្រីមិនស៊ីស្លែនេះទេ។ អ្នកខ្លះក៏ឡើងរមាស់ស្បែក នៅពេលប៉ះស្លែប្រភេទនេះ។



ការកើតមានស្លែប្រភេទថ្មី, ភូមិកោះច្បារ, 2022។
រូបថត៖ ហែម វណ្ណារ៉េត



ការកើតមានស្លែប្រភេទថ្មី, ភូមិកោះច្បារ, 2023។
រូបថត៖ ម៉ម ពេជ្យ



កូនកោះថ្ម នៅក្នុងទន្លេមេគង្គ ភូមិកោះច្បារ។ ដោយសារតែកម្រិតទឹករដូវប្រាំងនៅតែមានកម្រិតខ្ពស់ វាបានបណ្ដាលឱ្យកូនកោះខ្សាច់និងកូនកោះថ្មតូចៗជាច្រើននៅលិចក្រោមទឹក មិនបានផុសចេញឡើង, 2022។ រូបថត៖ ហែម វណ្ណារ៉េត



## កោះខ្សាច់និងថ្មបានលិចបាត់

នៅរដូវប្រាំង ទឹកនៅតែមានកម្ពស់ខ្ពស់ បណ្ដាលឱ្យកោះខ្សាច់និងថ្មជាច្រើនលែងផុសចេញមក។ ប្រជាជននៅភូមិចារថ្មោលធ្លាប់ដើរឆ្លងទន្លេក្នុងរដូវប្រាំងទៅកោះព្រាល ប៉ុន្តែឥឡូវវាលិចបាត់ហើយ។ ដូចគ្នានេះដែរ ផ្ទាំងថ្មជាច្រើនដែលធ្លាប់ផុសឡើងក្នុងរដូវប្រាំង ឥឡូវលែងមានឃើញទៀតហើយ។ ដើមឈើតូចៗ និងស្លែដែលធ្លាប់ដុះនៅលើថ្មទាំងនោះក្នុងរដូវប្រាំងបានផ្ដល់ជាអាហារនិងទីជម្រកដល់ត្រីក្នុងរដូវវស្សា។ បើនិយាយពីអត្ថប្រយោជន៍ការលិចលុបផ្ទាំងថ្មនិងទឹកជួរ មានអត្ថប្រយោជន៍មួយគឺវាបានបង្កភាពងាយស្រួលដល់ប្រជាជននៅកោះច្បារក្នុងការធ្វើដំណើរតាមទូក។

## 4.5 ការយល់ដឹងរបស់ប្រជាជនអំពីមូលហេតុនៃការប្រែប្រួលរបស់ទន្លេ

ប្រជាជនដែលចូលរួមក្នុងការស្រាវជ្រាវភាគច្រើនគិតថា ពួកគាត់ដឹងអំពីមូលហេតុនៃការប្រែប្រួលទន្លេដូចជា ការឡើងស្រកមិនទៀងទាត់ ការថយ-ចុះនៃបរិមាណត្រី ការបាក់ខូចច្រាំងទន្លេ ការបាត់បង់សួនដំណាំ និងការថយចុះគុណភាពទឹក។ ប្រជាជនភាគច្រើនលើកឡើងអំពីមូលហេតុចំនួនបួនគឺ៖ 1) ការអភិវឌ្ឍន៍គម្រោងវារីអគ្គិសនីខ្នាតធំនៅខ្សែទឹកខាងលើ។ 2) ការនេសាទខុសច្បាប់ 3) ការចោលសំរាមនិងកាកសំណល់ទៅក្នុងទន្លេ និង 4) ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្ត-រាយធម្មជាតិ។

ទាក់ទងនឹងគម្រោងវារីអគ្គិសនីនៅផ្នែកខាងលើដងទន្លេ ប្រជាជនលើកឡើងថា គម្រោងវារីអគ្គិសនីរារាំងដំណើរបម្លាស់ទីរបស់ត្រី និងបំផ្លាញជម្រកត្រីសំខាន់ៗ ដែលធ្វើឱ្យមានការថយចុះនូវបរិមាណត្រី និងប្រភេទសត្វរុក្ខជាតិដទៃទៀត។ ប្រជាជនខ្លះគាត់ក៏បាននិយាយដែរថា គម្រោងវារីអគ្គិសនីអាចបិទ ឬបើកទឹកបាន ដូច្នេះ វាបង្កឱ្យទឹកទន្លេមេគង្គមានការប្រែប្រួលកម្រិតទឹកខុសពីធម្មតាមិនទៀងទាត់ និងមិនអាចប៉ាន់ស្មានទុកជាមុនបានដែលប៉ះពាល់មិនត្រឹមតែផ្នែកជលផលប៉ុណ្ណោះទេ វាថែមទាំងធ្វើឱ្យច្រាំងទន្លេបាក់ស្រុត និងខូចបង់សួនដំណាំតាមមាត់ទន្លេផងដែរ។

ប្រជាជនក៏លើកឡើងផងដែរអំពីមូលហេតុដែលធ្វើឱ្យមានការថយចុះនៃធនធានត្រី គឺបណ្ដាលមកពីការនេសាទខុសច្បាប់ ដូចជាការការឆក់ត្រីជាដើម។ ប្រជាជនលើកឡើងថា ការនេសាទខុសច្បាប់បានកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក។ ក្រៅពីនេះ មូលហេតុមួយចំនួនទៀតមាន ការបាត់បង់ទីជម្រកត្រីពង ទីជម្រកត្រីមានជម្រៅទឹកកាន់តែរាក់ ហើយពេលខ្លះ កម្រិតទឹកស្រកខ្លាំងក្នុងរយៈពេលយូរ។

ប្រជាជនក៏បានលើកឡើងផងដែរអំពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ ដោយកត់សម្គាល់ឃើញថា ពេលខ្លះមានភ្លៀងខ្លាំងពេក ហើយពេលខ្លះក៏មានគ្រោះរាំងស្ងួតខ្លាំងផងដែរ។ នៅពេលភ្លៀងធ្លាក់ខ្លាំង ទឹកទន្លេបានកើនឡើងយ៉ាងរហ័សបណ្ដាលឱ្យជន់លិចតំបន់ខ្លះ បង្កឱ្យខូចខាតដល់ផ្ទះប្រជាពលរដ្ឋ ផ្លូវថ្នល់ ដំណាំកសិកម្ម និងទីជម្រកសត្វ។

ប្រជាជនបានកត់សម្គាល់ឃើញថា អ្នកស្រុកសំបូរមួយចំនួនចោលសំរាមពាសវាលពាសកាល ដែលធ្វើឲ្យទឹកទន្លេកាន់តែកខ្វក់ និងត្រូវបានបំពុលកាន់តែខ្លាំង។ ក្រៅពីនេះ មានក្រុមហ៊ុនស្ករត្នោតមួយនៅក្បែរភូមិកោះច្បារ ធ្លាប់ចោលកាកអំពៅចូលទន្លេ។ ក្រោយពីមានការត្អូញត្អែរពីប្រជាជនទើបក្រុមហ៊ុនបានកាត់បន្ថយការចោលកាកសំណល់ទៅក្នុងទន្លេ ប៉ុន្តែការចោលកាកសំណល់នៅតែកើតឡើង ដែលបណ្ដាលឱ្យប៉ះពាល់ដល់គុណភាពទឹក។

# 5. សេចក្ដីសន្និដ្ឋាន និងជំហានបន្ទាប់

> ទោះបីជាបច្ចុប្បន្នទន្លេរបស់យើងមានបញ្ហាបែបនេះក៏ដោយ ក៏យើងនៅមានត្រីខ្លះដែរ ហើយយើងនៅតែប្រើទឹកទន្លេរបស់យើងសម្រាប់ដាំដំណាំ។ និយាយរួមទៅ ទន្លេ វាអាចក្លាយជាកន្លែងទេសចរណ៍សំរាប់ឱ្យមនុស្ស មកកំសាន្តផងដែរ វាជាកន្លែងស្រស់ស្អាត មានខ្យល់អាកាសល្អសំរាប់មនុស្សនិងសត្វ។
>
> កសិករ អាយុ39ឆ្នាំ នៅភូមិចារថ្នោល

> ទន្លេជួយដល់ជីវិតមនុស្ស សត្វ រុក្ខជាតិ ហើយយើង មិនអាចរស់នៅដោយគ្មានទឹកបានទេ។
>
> មន្ត្រីរាជការ អាយុ50ឆ្នាំ នៅភូមិចារថ្នោល

> ទឹកទន្លេអាចឱ្យយើងប្រើបានប្រចាំថ្ងៃ មិនចាំបាច់ទិញទឹកគេនោះទេ។ យើងអាចស្រោចដំណាំដោយមិនចាំបាច់ចំណាយលុយទិញទឹក។
>
> ស្ត្រីមេផ្ទះ អាយុ28ឆ្នាំ នៅភូមិកោះច្បារ

> ទន្លេយើងសំខាន់ណាស់សម្រាប់យើងទាំងអស់គ្នា។ យើងគួរតែចេះប្រើប្រាស់វា និងរួមគ្នាថែរក្សាការពារទឹកទន្លេរបស់យើង។
>
> កសិករ ភេទស្រី អាយុ58ឆ្នាំ នៅភូមិកោះច្បារ

ថ្វីត្បិតតែការប្រែប្រួលរបស់ទន្លេមេគង្គ ប្រព័ន្ធអេកូឡូស៊ីរបស់ទន្លេ ធនធានត្រី និងធនធានព្រៃឈើ បានបង្កឱ្យមានបញ្ហាប្រឈមនិងការលំបាកចំពោះជីវភាពអ្នកភូមិកោះច្បារ និងភូមិចារថ្នោលក៏ដោយ ប្រជាជនភាគច្រើនបានលើកឡើងអំពីសារៈសំខាន់របស់ទន្លេមេគង្គ ដែលជាធនធានដ៏សំខាន់ដែលពួកគាត់មិនអាចខ្វះបាន។ នៅក្នុងឃ្លាសម្រង់សំដីរបស់ពួកគាត់ មានបង្ហាញពីបំណង និងការប្តេជ្ញាចិត្តក្នុងការថែរក្សានិងអភិរក្សទន្លេមេគង្គឱ្យបានល្អផងដែរ។

ដំណើរការនៃការស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍ក៏បានផ្តល់ឱកាសសម្រាប់អ្នកចូលរួមពិភាក្សាចែករំលែកអំពីការអភិវឌ្ឍន៍ណាដែលពួកគាត់ចង់បាន និងមិនចង់បាន (សូមមើលឃ្លាដកស្រង់សំដីប្រជាជន នៅក្នុងប្រអប់បន្ទាប់) និងអ្វីដែលពួកគាត់អាចរួមចំណែកក្នុងការកសាងអនាគតល្អប្រសើរ។ ប្រជាជនភាគច្រើនលើកឡើងថាការអភិវឌ្ឍន៍ដែលពួកគាត់មិនចង់បានគឺគម្រោងដែលធ្វើប្រជាជនលំបាកវេទនា ខូចខាតជីវភាព និងបំពានសិទ្ធិពលរដ្ឋ ហើយពួកគាត់ចង់ឃើញការអភិវឌ្ឍន៍ដែលជួយដោះស្រាយកង្វល់ និងបញ្ហាប្រឈមរបស់ប្រជាជន។ ប្រជាជនខ្លះបានលើកឡើងអំពីតម្រូវការកែលម្អហេដ្ឋារចនាសម្ពន្ធ និងសេវាសាធារណៈតាមមូលដ្ឋាន ដូចជា សាលារៀន ស្ពាន និងផ្លូវថ្នល់ ជាដើម។

ប្រជាជនបានបង្ហាញពីឆន្ទក្នុងការចូលរួមចំណែកក្នុងដំណើរការអភិវឌ្ឍន៍ ឧ. តាមរយៈការចូលរួមជាកម្លាំងពលកម្ម ការចូលរួមប្រជុំ ការរួមចំណែកថវិកា ការពិនិត្យដំណើរការអភិវឌ្ឍន៍ក្នុងសហគមន៍ ការចូលរួមសិក្សាស្រាវជ្រាវ និងការជួយគាំទ្រដល់អ្នកភូមិផ្សេងទៀត។ ការឆ្លើយតបទាំងនេះបង្ហាញថា ប្រជា-ជនចង់ចូលរួមចំណែក ក៏ដូចជាទទួលបាននូវអត្ថ-ប្រយោជន៍ពីគម្រោងអភិវឌ្ឍន៍នានា។

អ្នកចូលរួមក្នុងដំណើរការស្រាវជ្រាវជាច្រើនក៏បានបញ្ជាក់ផងដែរថា ពួកគាត់នឹងសប្បាយចិត្តប្រសិនបើអាជ្ញាធរមូលដ្ឋានមានផែនការដែលអនុញ្ញាតិឱ្យមានការចូលរួម។ ពួកគាត់សង្ឃឹមថាអាជ្ញាធរមូលដ្ឋាននឹងចែករំលែកព័ត៌មានបន្ថែមអំពីគម្រោងអភិវឌ្ឍន៍ដែលអាចប៉ះពាល់ដល់ភូមិនិងជីវភាពរស់នៅរបស់ពួកគាត់និងបញ្ចូលការចូលរួម និងសំឡេងរបស់ប្រជាពលរដ្ឋក្នុងការសម្រេចចិត្តអំពីកិច្ចការដែលប៉ះពាល់ដល់ពួកគាត់។ អាជ្ញាធរមូលដ្ឋានមានមតិកត់សម្គាល់ថា នៅពេលមានគម្រោងអភិវឌ្ឍន៍ រួមទាំងគម្រោងហេដ្ឋារចនាសម្ពន្ធខ្នាតធំដូចជាវារីអគ្គិសនីគួរតែមានការសិក្សាឱ្យបានត្រឹមត្រូវដើម្បីវាយតម្លៃផលប៉ះពាល់ដើម្បីចៀសវាងផលប៉ះពាល់ទៅលើជីវិតនិងជីវភាពប្រជាជន។

របាយការណ៍ស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍នេះ នឹងត្រូវបានចែករំលែកនិងប្រើប្រាស់ដើម្បីជួយសម្របសម្រួលដល់ការពិភាក្សាបន្ថែមទៀត រវាងប្រជាជក្នុងភូមិកោះច្បារ និងភូមិចារថ្នោល ដើម្បីស្វែងរកនិងចាត់អាទិភាពបញ្ហាប្រឈមសំខាន់ៗ ដែលពួកគាត់ចង់ដោះស្រាយ បន្ទាប់មកអាចដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍នៅតាមភូមិរៀងៗខ្លួន។

> ខ្ញុំសូមស្នើសុំទៅដល់រដ្ឋាភិបាល និងអ្នកវិនិយោគ កុំឱ្យមានគម្រោងវារីអគ្គិសនីនៅក្នុងភូមិរបស់យើង ពីព្រោះវានឹងធ្វើឱ្យមានការប៉ះពាល់ដល់ជីវិតប្រជាជនយើង និងធនធានធម្មជាតិរបស់យើង។
>
> កសិករ ភេទស្រី អាយុ35ឆ្នាំ
> នៅភូមិកោះច្បារ

> ខ្ញុំសូមឱ្យអ្នកវិនិយោគកុំសាងសង់ទំនប់វារីអគ្គិសនីអី ព្រោះវាប៉ះពាល់ដល់ជីវភាពរស់នៅ ដីធ្លី ផ្ទះសម្បែង សត្វ វប្បធម៌ប្រពៃណី និងធនធានផ្សេងទៀត។
>
> អ្នកនេសាទ ភេទប្រុស អាយុ42ឆ្នាំ
> នៅភូមិចារថ្នោល

> យើងខ្ញុំសូមស្នើសុំថា ពេលមានគម្រោងអភិវឌ្ឍណាមួយ ត្រូវជូនដំណឹងដល់ប្រជាពលរដ្ឋជាមុនសិន ដើម្បីកុំឲ្យការអភិវឌ្ឍប៉ះពាល់ដល់ប្រជាពលរដ្ឋ។
>
> អ្នកលក់ដូរ ភេទប្រុស អាយុ42ឆ្នាំ
> នៅភូមិចារថ្នោល

> ចង់ឃើញមានការគោរពទស្សនៈប្រជាជនជាធំ។
>
> ស្ត្រីមេផ្ទះ អាយុ42ឆ្នាំ នៅភូមិចារថ្នោល

> ខ្ញុំចង់ឲ្យរដ្ឋាភិបាលយើងបង្កើតគម្រោងដែលជួយដល់ជីវភាពរស់នៅរបស់ប្រជាជន ធ្វើយ៉ាងណាកុំឱ្យជីវភាពកាន់តែយ៉ាប់យឺន។
>
> កសិករ ភេទប្រុស អាយុ43ឆ្នាំ នៅភូមិកោះចារ

> សូមកុំមានគម្រោងអភិវឌ្ឍន៍ដែលធ្វើឲ្យប៉ះពាល់ដល់ប្រជាពលរដ្ឋ និងទ្រព្យសម្បត្តិប្រជាពលរដ្ឋ។
>
> កសិករ ភេទប្រុស អាយុ52ឆ្នាំ នៅភូមិចារត្នោល

> សូមគិតគូរដល់ប្រជាជនជាធំ។
>
> អ្នកនេសាទ ភេទប្រុស អាយុ50ឆ្នាំ
> នៅភូមិចារថ្នោល

> យើងខ្ញុំសូមស្នើសុំគម្រោងដែលមានជួយលើផ្នែកគ្រាប់ពូជធម្មជាតិ ជីធម្មជាតិ ទឹកស្អាត និងអនាម័យ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន។
>
> កសិករ ភេទប្រុស អាយុ37ឆ្នាំ នៅភូមិចារថ្នោល

> សូមឲ្យរដ្ឋាភិបាលសាងសង់ស្ពាន និងផ្លូវថ្នល់សម្រាប់ភូមិយើង។
>
> កសិករ ភេទស្រី អាយុ51ឆ្នាំ នៅភូមិកោះច្បារ

# ឯកសារឧបសម្ព័ន្ធ



ស្ពានឈើចាស់ទ្រុឌទ្រោម ឆ្លងដៃទន្លេមេគង្គ, អាចឆ្លងបានសម្រាប់អ្នកដំណើរថ្មើរជើង កង់ ម៉ូតូ ឬរ៉ឺម៉កធុនស្រាល, 2022។ រូបថត៖ ជឹម ចំរើន

## ឧបសម្ព័ន្ធទី1៖ ក្រុមការងារស្រាវជ្រាវសកម្មភាពដែលដឹកនាំដោយសហគមន៍ ភូមិកោះច្បារនិងភូមិចារថ្កោល

| ល.រ | ក្រុមការងារស្រាវជ្រាវ ភូមិកោះច្បារ | ល.រ | ក្រុមការងារស្រាវជ្រាវ ភូមិចារថ្កោល |
|---|---|---|---|
| 1 | ខុន លីតា (ស) (យុវជន) | 1 | កែ ធានី (ស) (យុវជន) |
| 2 | សេង ចាន់ថន (ស) | 2 | ពៅ ម៉ាឡី (ស) (យុវជន) |
| 3 | ម៉ម ពេជ្យ (ស) | 3 | ម៉ុន ភីនថង (ស) (យុវជន) |
| 4 | ហុង លឹមហ៊ន (ស) | 4 | សេង សុភ័ក្ត្រនី (ស) (យុវជន) |
| 5 | ជិន សែម (ប) | 5 | ភាន វឌ្ឍនី (ស) (យុវជន) |
| 6 | ឆែម តុលា (ប) | 6 | ជន់ អូនហេ (ស) (យុវជន) |
| 7 | សែង ប៊ូឡូ (ប) | 7 | ប៉ែន សំអឿន (ប) |
| 8 | ឡេង លី (ប) | 8 | ម៉ាន់ ណន (ប) |
| 9 | ឆៃ សំអ៊ី (ប) | 9 | ប៊ិន ខេម៉ា (ប) |
| 10 | សំ ធី (ប) | 10 | ទុន ស្រីទី (ស) |
| 11 | ទន ដួរ (ប) (យុវជន) | 11 | ម៉ណ ចារីរ (ស) |
| 12 | សំ ស្រីគេត (ស) (យុវជន) | 12 | រឿន ណារី (ស) |
| 13 | កាំង គឹមឆន (ប) | 13 | សេង សុនីតា (ស) |
| 14 | នន់ ប៊ុនសឿន (ប) | | |
| 15 | សូ ភោទ (ប) | | |
| 16 | វ៉ាន់ សូខាន (ស) | | |

## ឧបសម្ព័ន្ធទី2៖ មុខរបររបស់ប្រជាជនដែលចូលរួមឆ្លើយសំណួរស្ទង់មតិ នៅភូមិកោះច្បារនិងភូមិចារថ្កោល

មុខរបររបស់ប្រជាជនដែលចូលរួមឆ្លើយសំណួរស្ទង់មតិ នៅភូមិកោះច្បារ (គិតជា%)




មុខរបររបស់ប្រជាជនដែលចូលរួមឆ្លើយសំណួរស្ទង់មតិ នៅភូមិចារថ្កោល (គិតជា%)



## ឧបសម្ព័ន្ធ3ក៖ បរិមាណត្រីដែលរកបានក្នុងមួយជើង- 10ឆ្នាំមុន ធៀបនឹងឆ្នាំ2022

| # លេខ | កោះច្បារ (បរិមាណត្រីរកបានក្នុង1ជើង) | | ចារថ្មោល (បរិមាណត្រីរកបានក្នុង1ជើង) | |
|---|---|---|---|---|
| | 10ឆ្នាំមុន | 2022 | 10ឆ្នាំមុន | 2022 |
| 1 | 40គ.ក-50គ.ក | 2គ.ក-1គ.ក | 30គ.ក-40គ.ក | មិនមានចម្លើយ |
| 2 | 30គ.ក-50គ.ក | 2គ.ក | 40គ.ក-50គ.ក | 2គ.ក-3គ.ក |
| 3 | 30គ.ក-40គ.ក | 1គ.ក-2គ.ក | 30គ.ក-60គ.ក | 3គ.ក-4គ.ក |
| 4 | 20គ.ក-30គ.ក | 2គ.ក | 40គ.ក-60គ.ក | 1គ.ក-6គ.ក |
| 5 | 30គ.ក-50គ.ក | 1គ.ក | 40គ.ក-70គ.ក | 4គ.ក-5គ.ក |
| 6 | 5គ.ក | 1គ.ក | 30គ.ក-50គ.ក | 3គ.ក-6គ.ក |
| 7 | 20គ.ក-40គ.ក | 3គ.ក | 30គ.ក-40គ.ក | 4គ.ក-5គ.ក |
| 8 | 50គ.ក-60គ.ក | 1គ.ក-2គ.ក | 30គ.ក-40គ.ក | 2គ.ក-5គ.ក |
| 9 | 5គ.ក-10គ.ក | 1គ.ក | 20គ.ក-40គ.ក | 2គ.ក-5គ.ក |
| 10 | 10គ.ក | 2គ.ក | 40គ.ក-60គ.ក | 2គ.ក-5គ.ក |
| 11 | 30គ.ក-40គ.ក | 3គ.ក | 40គ.ក-60គ.ក | 2គ.ក-4គ.ក |
| 12 | 3គ.ក-4គ.ក | 2គ.ក | 20គ.ក-30គ.ក | 2គ.ក-4គ.ក |
| 13 | 10គ.ក-15គ.ក | 2គ.ក | 20គ.ក-30គ.ក | 2គ.ក-3គ.ក |
| 14 | 10គ.ក | 1គ.ក-2គ.ក | 30គ.ក-50គ.ក | 2គ.ក-6គ.ក |
| 15 | មិនមានចម្លើយ | មិនមានចម្លើយ | 50គ.ក-60គ.ក | 2គ.ក-5គ.ក |
| 16 | 10គ.ក | 2គ.ក | 30គ.ក-35គ.ក | 2គ.ក-5គ.ក |
| 17 | 10គ.ក | 2គ.ក | 30គ.ក-50គ.ក | 2គ.ក-4គ.ក |
| 18 | 10គ.ក | 2គ.ក | 40គ.ក-50គ.ក | 2គ.ក-3គ.ក |
| 19 | មិនមានចម្លើយ | មិនមានចម្លើយ | 50គ.ក-70គ.ក | 2គ.ក-5គ.ក |
| 20 | មិនមានចម្លើយ | មិនមានចម្លើយ | 50គ.ក-70គ.ក | 2គ.ក-4គ.ក |
| 21 | 30គ.ក-50គ.ក | 2គ.ក | 40គ.ក-50គ.ក | 1គ.ក-2គ.ក |
| 22 | 30គ.ក-40គ.ក | 2គ.ក | 30គ.ក-40គ.ក | 1គ.ក |
| 23 | 30គ.ក-50គ.ក | 2គ.ក | 40គ.ក-50គ.ក | 1គ.ក-2គ.ក |
| 24 | 20គ.ក-40គ.ក | 1គ.ក | 50គ.ក-60គ.ក | 1គ.ក |
| 25 | 30គ.ក-50គ.ក | 1គ.ក | 50គ.ក-87គ.ក | 1គ.ក-2គ.ក |
| 26 | 10គ.ក-30គ.ក | 2គ.ក | 30គ.ក-50គ.ក | 2គ.ក-4គ.ក |
| 27 | 40គ.ក-50គ.ក | 1គ.ក | 30គ.ក-50គ.ក | 1គ.ក-2គ.ក |
| 28 | 30គ.ក-40គ.ក | 1គ.ក | 50គ.ក-80គ.ក | 2គ.ក-5គ.ក |
| 29 | 15គ.ក-30គ.ក | 2គ.ក | 50គ.ក-70គ.ក | 1គ.ក-2គ.ក |
| 30 | 10គ.ក-15គ.ក | 2គ.ក | 30គ.ក-60គ.ក | 2គ.ក-3គ.ក |
| 31 | 20គ.ក-30គ.ក | 3គ.ក | 20គ.ក-40គ.ក | 1គ.ក-2គ.ក |
| 32 | 10គ.ក | 2គ.ក | 50គ.ក-100គ.ក | 1គ.ក-2គ.ក |
| 33 | 5គ.ក-10គ.ក | 2គ.ក | 40គ.ក-50គ.ក | 2គ.ក-3គ.ក |
| 34 | 10គ.ក | 2គ.ក | 40គ.ក-70គ.ក | 1គ.ក-2គ.ក |
| 35 | 10គ.ក-15គ.ក | 2គ.ក | 50គ.ក-70គ.ក | 1គ.ក-2គ.ក |
| 36 | 15គ.ក-20គ.ក | 3គ.ក | 60គ.ក-90គ.ក | 1គ.ក-3គ.ក |
| 37 | 10គ.ក-20គ.ក | 2គ.ក | 30គ.ក-70គ.ក | 1គ.ក-2គ.ក |
| 38 | 15គ.ក-30គ.ក | 2គ.ក | 40គ.ក-70គ.ក | 2គ.ក-1គ.ក |
| 39 | មិនមានចម្លើយ | មិនមានចម្លើយ | 60គ.ក-80គ.ក | 1គ.ក-2គ.ក |
| 40 | 20គ.ក-30គ.ក | 1គ.ក | 50គ.ក-60គ.ក | 2គ.ក-4គ.ក |
| 41 | មិនមានចម្លើយ | មិនមានចម្លើយ | 50គ.ក-80គ.ក | 1គ.ក-3គ.ក |
| 42 | 10គ.ក-15គ.ក | 2គ.ក | 42គ.ក-70គ.ក | 2គ.ក-3គ.ក |
| 43 | មិនមានចម្លើយ | មិនមានចម្លើយ | 30គ.ក-70គ.ក | 2គ.ក-3គ.ក |
| 44 | 5គ.ក-10គ.ក | 2គ.ក | 40គ.ក-50គ.ក | 2គ.ក-1គ.ក |
| 45 | 20គ.ក-40គ.ក | 1គ.ក-2គ.ក | 40គ.ក-70គ.ក | 1គ.ក-2គ.ក |
| 46 | 10គ.ក | 1គ.ក | 20គ.ក-40គ.ក | 2គ.ក-3គ.ក |
| 47 | 10គ.ក-15គ.ក | 0.5គ.ក | 50គ.ក-60គ.ក | 1គ.ក-2គ.ក |
| 48 | 10គ.ក-15គ.ក | 0.5គ.ក | 40គ.ក-70គ.ក | 1-គ.ក |
| 49 | 10គ.ក-15គ.ក | 0.5គ.ក | | |
| 50 | 20គ.ក-40គ.ក | 2គ.ក | | |
| 51 | 5គ.ក-10គ.ក | 0.5គ.ក | | |
| 52 | 5គ.ក-10គ.ក | 1គ.ក-2គ.ក | | |
| 53 | 10គ.ក-15គ.ក | 1គ.ក-2គ.ក | | |
| 54 | 20គ.ក-30គ.ក | 1គ.ក-2គ.ក | | |
| 55 | 20គ.ក-25គ.ក | 1គ.ក | | |

## ឧបសម្ពន្ធ3ខ៖ ពូជត្រីដែលរកបាននៅភូមិកោះច្បារ និងភូមិចារថ្លោល ក្នុងឆ្នាំ2022

| ល.រ | ពូជត្រី | រកបាននៅភូមិកោះច្បារ | រកបាននៅភូមិចារថ្លោល |
|---|---|---|---|
| 1 | ត្រីចង្វា | ✓ | |
| 2 | ត្រីរៀល | ✓ | ✓ |
| 3 | ត្រីខ្យល់ | ✓ | ✓ |
| 4 | ត្រីឈ្វាត | ✓ | |
| 5 | ត្រីអាចម៍កុក | ✓ | ✓ |
| 6 | ត្រីស្រកាក្តាម | ✓ | |
| 7 | ត្រីទ្រនុងខ្នង | ✓ | |
| 8 | ត្រីកញ្ជាញ់ច្រាស | ✓ | |
| 9 | ត្រីឆ្លាំង | ✓ | |
| 10 | ត្រីច្រកែង | ✓ | ✓ |
| 11 | ត្រីលលកសរ | ✓ | ✓ |
| 12 | ត្រីអាចម៍កុក ឬអាចម៍ស្វា ឬប៉ាភៀន | ✓ | ✓ |
| 13 | ត្រីផ្ទក់ | ✓ | |
| 14 | ត្រីស្លឹកឫស្សី | ✓ | |
| 15 | ត្រីក្អែក | ✓ | ✓ |
| 16 | ត្រីកញ្ចុះ | ✓ | ✓ |
| 17 | ត្រីគល់ព្រេច | ✓ | ✓ |
| 18 | ត្រីអណ្តែង | ✓ | ✓ |
| 19 | ត្រីក្រាញ់ | ✓ | ✓ |
| 20 | ត្រីឆ្លូញ | ✓ | |
| 21 | ត្រីខ្ញឹង | ✓ | |
| 22 | ត្រីដំរី | ✓ | |
| 23 | ត្រីខ្លា | ✓ | |
| 24 | ត្រីឆ្ពោកក្តារ | ✓ | |
| 25 | ត្រីឆ្ពិន | ✓ | ✓ |
| 26 | ត្រីប៉ាលូង | ✓ | |
| 27 | ត្រីប្រាកណ្តុរ | ✓ | ✓ |
| 28 | ខ្យាក្រហម | ✓ | |
| 29 | ត្រីឆ្ពោកក្តារ | ✓ | |
| 30 | ត្រីខ្យា | ✓ | |
| 31 | ត្រីខ្មាន់ | ✓ | |
| 32 | ត្រីកែស | | ✓ |
| | សរុប | 31 | 14 |

## ឧបសម្ព័ន្ធទី3គ៖ ពូជត្រីកម្រឃើញមាន ឬកម្ររកបាននៅឆ្នាំ2022 នៅភូមិកោះច្បារ និងភូមិចារថ្នោល

| ល.រ | ពូជត្រី | ពូជត្រីកម្រឃើញនៅភូមិកោះច្បារ | ពូជត្រីកម្រឃើញនៅភូមិចារថ្នោល |
|---|---|---|---|
| 1 | ត្រីដំរី | | ✓ |
| 2 | ត្រីសណ្ដាយ | ✓ | ✓ |
| 3 | ត្រីក្ដី | ✓ | ✓ |
| 4 | ត្រីក្រាយ | ✓ | ✓ |
| 5 | ត្រីពោ | ✓ | ✓ |
| 6 | ត្រីរមាស | ✓ | ✓ |
| 7 | ត្រីឆ្កោកក្ដារ | | ✓ |
| 8 | ត្រីស្ទូក់ | ✓ | ✓ |
| 9 | ត្រីប្រា | ✓ | ✓ |
| 10 | ត្រីប៉ាលូង | | ✓ |
| 11 | ត្រីកែស | ✓ | |
| 12 | ខ្យាក្រហម | | ✓ |
| 13 | ត្រីក្លាំងហាយ | ✓ | ✓ |
| 14 | ត្រីត្រសក់ | ✓ | ✓ |
| 15 | ត្រីឆ្កោកមូល | ✓ | ✓ |
| 16 | ត្រីឆ្លាំង | | ✓ |
| 17 | ត្រីគ្រុំ | ✓ (តូចៗ) | ✓ (តូចៗ) |
| 18 | ត្រីខ្យា | | ✓ |
| 19 | ត្រីខ្មាន់ | | ✓ |
| 20 | ត្រីក្រយ៉ា | ✓ | ✓ |
| 21 | ត្រីក្របី/កន្ធន់ដី | ✓ | ✓ |
| 22 | ត្រីផ្ទក់ | | ✓ |
| 23 | ត្រីប៉ាលូង | | ✓ |
| 24 | ត្រីឆ្កោក | ✓ | ✓ |
| 25 | ត្រីទ្រនេល | ✓ | ✓ |
| 26 | ត្រីដៀប | ✓ | |
| 27 | ត្រីចង្វា | | ✓ |
| 28 | ត្រីកញ្ចាញ់ច្រាស | | ✓ |
| 29 | ត្រីឈ្វាត | | ✓ |
| 30 | ត្រីស្រកាក្ដាម | | ✓ |
| 31 | ត្រីទ្រនុងខ្នង | | ✓ |
| 32 | ត្រីកញ្ចាញ់ច្រាស | | ✓ |
| 33 | ត្រីស្លឹកឬស្សី | | ✓ |
| 34 | ត្រីឆ្លូញ | | ✓ |
| 35 | ត្រីខ្ទឹង | | ✓ |
| 36 | ត្រីប៉ាស៊ីអ៊ី | | ✓ |
| 37 | ត្រីក្រយ៉ាខ្មៅ | | ✓ |
| | សរុប | **17** | **35** |

## ឧបសម្ពន្ធទី3យ៖ ពូជត្រីដែលលែងឃើញមាន ឬរកលែងបាននៅឆ្នាំ2022

| ល.រ | ពូជត្រី | ពូជត្រីដែលអ្នកភូមិប្រាប់ថាលែងឃើញមាន ឬលែងរកបាននៅឆ្នាំ2022 នៅភូមិកោះច្បារ | ពូជត្រីដែលអ្នកភូមិប្រាប់ថាលែងឃើញមាន ឬលែងរកបាននៅឆ្នាំ2022 នៅភូមិចារថ្នោល |
|---|---|---|---|
| 1 | ត្រីគល់រាំង | ✓ | ✓ |
| 2 | ត្រីព្រួល | ✓ | |
| 3 | ត្រីប៉ាសាអ៊ី | ✓ | |
| 4 | ត្រីប៉ាវ៉ា | ✓ | ✓ |
| 5 | ត្រីអំបូង | ✓ | ✓ |
| 6 | ត្រីក្រយ៉ាខ្មៅ | ✓ | |
| 7 | ត្រីរាហូ | ✓ | ✓ |
| 8 | ត្រីខ្លា | | ✓ |
| 9 | ត្រីគុងទីន | ✓ | ពុំមាន* |
| 10 | ត្រីពពែសរ | ✓ | ពុំមាន* |
| 11 | ត្រីរាជ | ✓ | ✓ |
| | **Total** | **10** | **6** |

*ពុំមាន៖ ពូជត្រីនេះពុំដែលឃើញមាននៅក្នុងភូមិពីមុនមកទេ។



ត្រីតូចៗកំពុងត្រូវបានហាលនៅផ្ទះ នៅភូមិកោះច្បារ, 2023។ រូបថត៖ ជឹម ចំរើន


INTERNATIONAL
RIVERS
people • water • life
FLO
Building Resourceful Communities